BMI0102

# សម្ភាសន៍ជាមួយឈ្មោះ រឿម សារ៉េត ភេទប្រុស អាយុ៥២ឆ្នាំ

## មុខងាររជនាន់ខ្មែរក្រហម“កងចល័ត”

## រស់ភូមិម៉ៅ ឃុំផ្គាំ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១០

## សម្ភាសន៍ដោយៈ សោម ប៊ុនថន

## ០១:២១:៥៤

## ៣៩ទំព័រ

ប៊ុនថនៈ ចឹងជាដំបូងខ្ញុំចង់សួរឈ្មោះ ពូ ពូឈ្មោះអីដែរ?

សារ៉េតៈ ខ្ញុំឈ្មោះ រៀម សារ៉េត ។

ប៊ុនថនៈ រៀម សារ៉េត?

សារ៉េតៈ បាទ ។

ប៊ុនថនៈ ពូអាយុប៉ុន្មានហើយពូ?

សារ៉េតៈ អាយុ៥២ឆ្នាំ ។

ប៊ុនថនៈ ពូមានស្រុកកំណើតនៅណាពូ?

សារ៉េតៈ ស្រុកកំណើតខ្ញុំនៅភូមិកូឡាបពាស ឃុំបាយដំរ៉ាម ស្រុកបាណន ខេត្តបាត់ដំបង ។

ប៊ុនថនៈ បាទ!ពូមានបងប្អូនប៉ុន្មាននាក់?

សារ៉េតៈ បងប្អូនខ្ញុំមានប្រុសបីនាក់ ស្រីបីនាក់ ។

ប៊ុនថនៈ ពូកូនទីប៉ុន្មានពូ?

សារ៉េតៈ ខ្ញុំកូនទីបី ។

ប៊ុនថនៈ ពូរៀនដល់ថ្នាក់ទីប៉ុន្មានដែរ?

សារ៉េតៈ ខ្ញុំរៀនកាលសម័យនោះដួបប្រទះនិងសង្គ្រាមសម័យសាធារណរដ្ឋហ្នឹង ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ ខ្ញុំរៀននៅវត្តមិនមានទាន់ថ្នាក់ទេណាស់ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ ដល់ពេលហ្នឹងខ្ញុំក៏មានវ័យអាយុ១៨ឆ្នាំ គេមិនឲ្យយើងនៅបួសរៀនទេ ធ្វើបួសជាលោកសង្ឃអីទេ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ គេមានការដេញចាប់ធ្វើជាស្ម័យគ្រានឬក៏ធ្វើជាទាហានសម័យលន់ នល់ហ្នឹងណាស់ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ ដល់ចឹងទៅខ្ញុំរៀនហ្នឹងមិនមានថ្នាក់ពិតប្រាកដទេ ចូលទៅចូលទៅនៅនិងវត្តលោក ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ រៀនជាធម៌បួស រៀនជាអក្សរបណ្ដើរនៅពេលដែលចេះអានចេះសរសេរហើយគេឲ្យរៀនជាធម៌បួស ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ នៅពេលដែលខ្ញុំទៅនៅបានបីឆ្នាំខ្ញុំមានអាយុដល់១៥ឆ្នាំហើយ ។

ប៊ុនថនៈ ចឹងអាយុ១៥ហើយ?

សារ៉េតៈ បាទ!ដល់ពេលហ្នឹងគេចាប់ខ្ញុំឲ្យទៅធ្វើជាទាហាន គេដេញចាប់ ដល់ដេញចាប់ខ្ញុំនៅវត្តមិនបានខ្ញុំរត់មកនៅស្រុកស្រែចំការវិញគេចាប់បានទៅធ្វើជាទាហានជាមួយគេបានបីខែ ខ្ញុំប៉ះបងខ្ញុំគាត់ធ្វើទាហានលន់ នល់ហ្នឹងគាត់មានគាត់ពាកសក្ដិ១ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ ក៏គាត់បណ្ដោះខ្ញុំឲ្យមកផ្ទះវិញមក មកដល់ផ្ទះវិញហ្នឹងអាជ្ញាធរភូមិហ្នឹងគេតែងតាំងឲ្យខ្ញុំធ្វើស្ម័យគ្រានការពារភូមិកាន់អាវុធសម័យហ្នឹងឆ្នាំ៧៤ ។

ប៊ុនថនៈ ខាងនេះទេ ខាងសាធារណរដ្ឋទេ?

សារ៉េតៈ បាទ!ខាងសាធារណរដ្ឋទេ ។

ប៊ុនថនៈ ចឹងពូមានបានបួសដែលពូ?

សារ៉េតៈ អត់បានបួសទេ ទើបតែនៅវត្តជិតមួយឆ្នាំ ។

ប៊ុនថនៈ រៀនជាមួយគ្រូ លោកជាអ្នកបង្រៀន?

សារ៉េតៈ បាទ!លោកអ្នកបង្រៀន ។

ប៊ុនថនៈ តែអាចអានបានទេ?

សារ៉េតៈ អាចបានមើលបាន ។

ប៊ុនថនៈ ចឹងពូមកនៅស្ម័យគ្រានភូមិហ្នឹង ពូនៅបានយូរទេ?

សារ៉េតៈ ខ្ញុំនៅបានពីឆ្នាំ៧៤ដល់ឆ្នាំ៧៥វាបានពេញមួយឆ្នាំ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ ដល់ចូលឆ្នាំ៧៥គេ ប៉ុល ពតគេចូលមកខ្មែរក្រហមគេចូលមករំដោះដកអាវុធដកអីអស់ទៅ ក៏គេបញ្ជូនខ្ញុំឲ្យទៅនៅជាក្រុមកុមារ ឲ្យក្តោមក្តាប់កុមារជំនាន់ឆ្នាំ៧៥ គេធ្វើជាកងចល័តនោះណាស់ ។

ប៊ុនថនៈ បាទ!កុមារក្នុងភូមិពូ?

សារ៉េតៈ បាទ!កុមារក្នុងភូមិសម្រាប់ដឹកនាំកុមារមួយក្រុមហ្នឹងឲ្យឃ្វាលជាគោ១០០ទៅ២០០ក្បាលទៅណាស់ ។

ប៊ុនថនៈ បាទ!តែការហ្នឹងខ្មែរក្រហមមានដឹងថាពូជាកងស្វាយត្រានអីទេ?

សារ៉េតៈ បាទ!គេដឹងប៉ុនខ្ញុំនៅក្មេងគេអត់ដូចជាមិនសូវជាចាប់អារម្មណ៍ណាស់ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ គេចាប់អារម្មណ៍ទៅលើមនុស្សដែលមានអាយុចាប់ពី២០ឬពី១៨ឡើងទៅយ៉ាងតិច ព្រោះខ្ញុំនៅក្នុងសម័យនោះខ្ញុំនៅស្វាយត្រានហ្នឹងខ្ញុំមានអាយុ១៣ទៅ១៨ឆ្នាំនៅឡើយ ។

ប៊ុនថនៈ បាទ!នៅក្មេង?

សារ៉េតៈ បាទ ។

ប៊ុនថនៈ ចឹងកាលនៅក្មេងចឹងពូមានកាន់កាំភ្លើងកាន់អីដែរ?

សារ៉េតៈ បាទ!កាំភ្លើងគេឲ្យ ពីដើមមិញគេហៅកាំភ្លើងកាលីប៊ិនហ្នឹង ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ គេចែកឲ្យមានគ្រាប់មានកាំភ្លើងមានទុសសៀអីចឹងទៅ ហើយយប់ឡើងគេធ្វើរបងចឹងគេធ្វើរបងហើយគេវៃក្រឡាចឹងទៅគេឲ្យយើងមានគ្រាប់បែកមានកាំភ្លើងហើយធ្វើកូនប៉ុស្តិមួយតូចៗសម្រាប់អង្គុយយាមផ្លាស់ផ្តូគ្នា ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ ខ្មាចខ្មែរក្រហមវាចូលមកដុតភូមិ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ គេការពារល្អណាស់កន្លែងហ្នឹង ។

ប៊ុនថនៈ ប៉ុន្តែដែលចូលមកទេ?

សារ៉េតៈ ចូលមកបានពីរដង តែចូលមកហ្នឹងវាអត់បានចូលមកធ្វើបាបអ្នកស្រុកកើតទេ អ្នកស្រុករត់ឆ្លងមកនៅម្ខាងស្ទឹងអស់ទៅ នៅសល់ពួកខ្ញុំស្វាយត្រាននិងបាញ់ទប់ទល់ជាមួយវា តែបាញ់វាតែចុះឯង ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ វាចូលមកវាដុតផ្ទះមួយខ្នងពីរខ្នងចោលវាទៅវិញ ។

ប៊ុនថន៖ តែអត់មានរបួសទេ?

សារ៉េត៖ អត់មានទេ អត់មានរបួសទេគ្រោះថ្នាក់អីទេ ព្រោះមានបន្ទាយទាហានមកជិត ។

ប៊ុនថន៖ បាទ!ចឹងពូមានខ្លាចដែលពូនៅក្មេងចឹង?

សារ៉េត៖ សម័យនោះខ្ញុំនៅខ្លាចនៅឡើយ ពេលនៅពេលឮថាខ្មែរក្រហមមកមានការភ័យខ្លាច ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ តែមានមនុស្សចាស់នៅជាមួយហ្នឹងគេថាកុំខ្លាចអាអូន ក្អែកយើងឲ្យតែរំពៃរមើលឃើញបាញ់មួយគ្រាប់គឺហើយ ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ គេដឹកនាំចឹងដល់ពេលគេចូលមកវៃ គេចូលមកគេអត់បុកចំកន្លែងខ្ញុំទេ គេបុកឆ្ងាយពីកន្លែងខ្ញុំ ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ ចំងាយប្រហែលជា៥០ម៉ែត្រ គេឆ្ងាយកន្លែងនោះអស់ខ្ញុំនៅមិនបានក៏រត់ឆ្លងស្ទឹងមកនៅក្រោយខាងលិចបានទាហានគេមកជួយ ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ ហើយកន្លែងហ្នឹងវាបៀតក្រុងបាត់ដំបងយន្តហោះគេឡើងទៅទាំងយប់ ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ គេទៅដាក់ភ្លើងភ្លឺចឹងទៅគេទៅបាញ់រះចឹងទៅវាក៏រត់ទៅវិញអស់ ។

ប៊ុនថន៖ បាទ!ចឹងពូរត់មកនៅខាងស្ទឹងនេះដាច់៧៥តែម្តងបានចូល?

សារ៉េត៖ អាហ្នឹងនៅក្នុងយប់មួយដែលគេឡើងវៃហ្នឹងនៅក្នុងឆ្នាំ៧៥ តែវានៅដើមឆ្នាំនៅឡើយ ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ ឆ្នាំនោះឯងវាវៃភូមិខ្ញុំពីរដងហើយយើងប្រកាសឲ្យដាក់អាវុធប្រគល់ឲ្យខ្មែរក្រហមឆ្នាំ៧៥នោះហើយ ។

ប៊ុនថន៖ បាទ ។

សារ៉េតៈ ដល់មកឆ្នាំ៧៦ ឆ្នាំ៧៥ ពេលគេបញ្ចប់ទៅដល់រដូវយើងធ្វើស្រែហ្នឹងគេយកមនុស្សយើងជាក្រុមៗជាគ្រួសារណា ចំនួន១៥គ្រួសារឬ២០គ្រួសារហ្នឹង គេយកទៅចងក្រងឲ្យធ្វើផ្ទះឲ្យនៅមួយក្តុបៗហើយធ្វើស្រែរួមគ្នា ។

ប៊ុនថន: បាទ ។

សារ៉េតៈ តែឆ្នាំងបាយនៅផ្សេងគ្នា ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ ដល់ពេលឆ្នាំ៧៦ អាហ្នឹងគេដកពួកខ្ញុំហើយឲ្យខ្ញុំទៅនៅធ្វើជាក្រុមចល័តពួកកំលោះកម្រុំហ្នឹង គេយកដាក់ផ្សេងគ្នា តែគេឲ្យធ្វើការរួមគ្នាគេឲ្យហូបបបរឆ្នាំងខ្ទះជុំគ្នាចេះ ។

ប៊ុនថនៈ ចឹងក្រោពីការងាររកងចល័តហ្នឹងពូមានធ្វើអីទៀតទេពូ?

សារ៉េតៈ នៅក្នុងចល័តហ្នឹងខ្ញុំមិនបានធ្វើជាក្រុមឬជាមេបក្សមេពួកអីទេ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ នៅជាសម័យសមាជិកគេ ។

ប៊ុនថនៈ បាទ!ចឹងការងារប្រចាំថ្ងៃ?

សារ៉េតៈ គេឲ្យទៅដំបូងគេឲ្យចងក្រងជាកងចល័តនោះគេឲ្យឆ្ការព្រៃ រួចឆ្ការព្រៃគេឲ្យលើកជាទំនប់ធ្វើជាប្រឡាយនាំទឹកយកទៅចោលនៅខាងស្រុកមោង ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ ខាងភ្នំប៉ាដេនោះខាងត្បូងបាត់ដំបង ដល់គេធ្វើប្រឡាយនិងបានចប់សព្វគ្រប់គេឲ្យមកផ្ទះវិញមកនៅផ្ទះបានមួយឆ្នាំនេះ គេប្រមូលដល់ខែប្រចូតចេះឯង គេប្រមូលទៅវិញគេយកទៅដាក់កន្លែងហ្នឹងគេហៅភូមិកំហតសព្វថ្ងៃហ្នឹងវានៅភស្តុតាងច្បាស់លាស់នៅឡើយកន្លែងហ្នឹង ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ វាមានស្ពានវាមានស្ទឹងគេធ្វើណាស់ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ ស្ទឹងពួកខ្ញុំជីកហ្នឹងវាមានជំរៅ២៥ម៉ែត្រហើយមាត់លើវា៥០ម៉ែត្រ ដីស្អាតចឹងគេឲ្យយើងជីកធ្វើជាស្ទឹងដល់រួចគេធ្វើស្ពានឆ្លងចាក់ថ្មបីតុងចឹងទៅគេធ្វើទ្វារបិតបើកទឹក ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ សព្វថ្ងៃរបស់ហ្នឹងវានៅជាស្នាដៃរបស់ពួកខ្ញុំធ្វើហ្នឹងគេនៅល្អនិងបណ្តោយ ។

ប៊ុនថនៈ ចឹងគេប្រើប្រាស់បាន?

សារ៉េតៈ បាទ!គេប្រើប្រាស់បានសព្វថ្ងៃ។

ប៊ុនថនៈ ចឹងពូមកនៅហ្នឹងចុះបងប្អូនពូ?

សារ៉េតៈ បងប្អូនខ្ញុំ ប្អូនស្រីខ្ញុំវានៅតូចៗទេគេមិនទាន់យកទៅប្រើការអីទេ?

ប៊ុនថនៈ បាទ។

សារ៉េតៈ ហើយប្អូនប្រុសមួយក៏មិនទាន់ប្រើមានតែបងខ្ញុំមួយបន្ទាប់ពីបងទីពីរហ្នឹងបន្ទាប់ពីខ្ញុំមានខ្ញុំនិងឯង។

ប៊ុនថនៈ បាទ។

សារ៉េតៈ គាត់រួចខ្ញុំមានតែពីរនាក់ហ្នឹងឯងដែលនៅចល័ត។

ប៊ុនថនៈ បាទ!ចឹងពូរបស់ពីម្នាក់ទៀតដែលធ្វើជាទាហានលន់ នល់ពាក់សក្តិ១ពេលហ្នឹងគាត់ទៅនៅ?

សារ៉េតៈ គាត់ស្លាប់នៅក្នុងឆ្នាំ៧៥ហ្នឹងឯង គាត់កើតរោគហៅថាទៀចទឹក ពោះប៉ោង។

ប៊ុនថនៈ បាទ។

សារ៉េតៈ គាត់កើតពោះប៉ោងនិងងាប់។

ប៊ុនថនៈ បាទ។

សារ៉េតៈ គាត់មិនមានពីណាសម្លាប់គាត់នៅក្នុងសម័យប៉ុល ពតទេ។

ប៊ុនថនៈ បាទ។

សារ៉េតៈ គាត់មានបុណ្យសក្តិពាក់មែនព្រោះគាត់នៅភូមិនេះ គាត់ទៅនៅប៉ៃលិនគាត់ធ្វើទាហានគាត់មានបុណ្យសក្តិ។

ប៊ុនថនៈ បាទ។

សារ៉េតៈ ពេលគាត់មកពីប៉ៃលិនមកនៅស្រុកកំណើតវិញ គេមិនដឹងថាគាត់និងប្រវត្តិជាអីទេ។

ប៊ុនថនៈ បាទ។

សារ៉េតៈ គេមិនទាន់ស្រាវជ្រាវរកដងគាត់ គាត់មានរោគគៀត្រូវស្លាប់ទៅ។

ប៊ុនថនៈ បាទ!ចុះឪពុកម្តាយលោកពូ?

សារ៉េតៈ ឪពុកម្តាយខ្ញុំស្លាប់នៅឆ្នាំ៨៤ ឆ្នាំ១៩៨៤។

ប៊ុនថនៈ តែការសម័យបីឆ្នាំហ្នឹងគាត់មានជម្លៀសទៅណាដែលលោកពូ?

សារ៉េតៈ អត់មានទៅណាទេ នៅក្នុងភូមិក្នុងស្រុកហ្នឹងឯង។

ប៊ុនថនៈ បាទ។

សារ៉េតៈ សម័យពីមុនមកគាត់អត់មានធ្វើអីទេណាស់ ដល់ពេលនៅក្នុងសម័យប៉ុល ពតគេឲ្យគាត់ធ្វើជាមេក្រុមចាស់ៗនៅក្នុងភូមិ ដឹកនាំមនុស្សចាស់ៗនៅក្នុងភូមិហ្នឹងធ្វើជាចំការធ្វើជាស្រែដំណាំ ដំណាំដាំដុះអីគាត់ជាអ្នកដឹកនាំគេ ។

ប៊ុនថនៈ បាទ!ភូមិពីហ្នឹង?

សារ៉េតៈ ភូមិកូឡាបពាស ។

ប៊ុនថនៈ ភូមិកូឡាបពាសហ្នឹងនៅភូមិរំដោះឬមួយភូមិចាស់គេ?

សារ៉េតៈ ភូមិហ្នឹងជាភូមិកំណើតខ្ញុំកើតជាឃើញភូមិហ្នឹងនៅហ្នឹង ចំងាយពីក្រុងបាត់ដំបង១២គីឡូ ។

ប៊ុនថនៈ ចឹងសម័យខ្មែរក្រហមហ្នឹងជាមូលដ្ឋានទើបរំដោះថ្មីឬគេហៅភូមិចាស់?

សារ៉េតៈ ភូមិចាស់អត់មានខ្មែរក្រហមអភិវឌ្ឍន៍ទេ ។

ប៊ុនថនៈ ចឹងអ្នកភូមិហ្នឹងជាប្រជាជនចាស់ឬប្រជាជនថ្មីពេលចូលដល់សម័យបដិវត្តណាស់ពូ?

សារ៉េតៈ ប្រជាជនចាស់យើងធម្មតា ។

ប៊ុនថនៈ ចឹងអត់មានជម្លៀសទៅណាទេ?

សារ៉េតៈ អត់មានទេ អត់មានជម្លៀសទេបើពួកអ្នកដែលមានវ័យកណ្ដាលគេធ្វើជាទាហានលន់ នល់អីអាហ្នឹងពួកខ្មែរក្រហមមានជម្លៀសយកចេញទៅនៅនេះទៅនៅនោះទៅក៏វាប្រឡំវៃចោលខ្លះទៅ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ ហើយអ្នកដែលនៅក្នុងភូមិហ្នឹងអតីតទាហានលន់ នល់ក៏មានរស់នៅអ្នកដែលធ្វើស៊ុយគ្រានដូចខ្ញុំចឹងមានរស់នៅ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ ព្រោះកន្លែងហ្នឹងមិនសូវមានអ្នកអុចអាលរឿងអតីតអ្នកតស៊ូច្បាំងជាមួយខ្មែរក្រហមណាស់កាលហ្នឹង ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ គេមិនសូវរុកគួនគ្នាទេ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ គេជួយលាក់បំពួនព្រោះថាមនុស្សក្នុងស្រុក ។

ប៊ុនថនៈ ចឹងមានអ្នកថ្មីមកជម្លៀសចូលក្នុងភូមិហ្នឹងទេ?

សារ៉េតៈ អ្នកដែលមកថ្មីមានប៉ុនសម្បូរតែជនជាតិចិន ។

ប៊ុនថន៖ ម៉េចចឹងពូ?

សារ៉េត៖ ព្រោះអកដែលនៅក្នុងនោះមានបងប្អូនចិនគាត់មកនៅទីតាំងក្នុងភូមិហ្នឹងពីសម័យដែលគាត់មករស់នៅតាំងពីនៅក្មេងៗណាស់ ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ ដូច្នេះគាត់មានបងប្អូនគាត់នៅបាត់ដំបងខ្លះនៅពោធិសាត់ខ្លះនៅភ្នំពេញចឹងទៅដល់ពេលគេបំបែកទីក្រុងទៅគេស្រាវជ្រាវគេរត់មកនៅតាមបងប្អូន ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ បងប្អូនគេឃិតយោងមកឲ្យមកនៅជាមួយ ។

ប៊ុនថន៖ ចឹងអ្នកដែលមកថ្មីហ្នឹងគេមានមែងចែកយ៉ាងម៉េចដែរ?

សារ៉េត៖ គេទុកជាប្រជាពលរដ្ឋធម្មតាអត់មានចាត់ទុកជាមនុស្សប្លុកឬក៏មនុស្សមកពីនេះពីនោះអីទេ គេចាត់ទុកជាមនុស្សក្នុងភូមិធម្មតាដូចគេចឹង ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ ការសម្លាប់រង្គាលមានរឿងមានហេតុអី មិនដែលមានអ្នកយកមកពីចំណូលនិងមកសម្លាប់មានតែស្លាប់អ្នកនៅក្នុងភូមិ ។

ប៊ុនថន៖ ម៉េចចឹងវិញ?

សារ៉េត៖ អ្នកដែលនៅក្នុងភូមិមូលដ្ឋានចាស់និងមានដូចថាអ្នកដែលធ្វើការហ្នឹងយើងសម័យនោះមានឈ្លបគេណាស់ ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ កាលណាដែលយើងគេប្រើយើងទៅ យើងមានសំដីមិនល្អនិងគេធ្វើឲ្យគេស្អប់ចឹងទៅគេរាយការណ៍ថាអ្នកនិងខ្ជិលលួចនេះលួចនោះយកទៅសម្លាប់ចោល ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ តែបើចំពោះអ្នកចំណូលថ្មីមិនមានស្លាប់ម្នាក់មួយទេ នៅរស់ទាំងអស់ ។

ប៊ុនថន៖ ចឹងរបបហូបចុកអីដូចគ្នាជាមួយអ្នកភូមិដែរ?

សារ៉េត៖ ដូចគ្នា ព្រោះសម័យនោះគេរើផ្ទះធំៗចេះយកទៅរៀបដូចយើងថាអាគារធំៗដូចជាសាលារៀនណាស់ ។

ប៊ុនថន៖ បាទ ។

សារ៉េត: គេធ្វើយ៉ាងចុះឯងហើយ ក្នុងនោះគេធ្វើជាបន្ទប់ចឹងទៅគេដាក់ស្រូវអង្ករក្នុងនោះ គេបញ្ចេញមកឲ្យយើងដាំបាយរាប់មនុស្សទៅដូចថា ក្នុងមនុស្សម្នាក់ចឹងគេឲ្យមួយកំប៉ុងសម្រាប់មួយថ្ងៃ ។

ប៊ុនថន: បាទ ។

សារ៉េត: មិនថាក្មេងមិនថាចាស់ទេ គេឲ្យស្មើរទាំងអស់គ្រប់រូបចឹងទៅគេយកទៅដាក់បបរឆ្នាំងខ្ទះគ្នោតធំៗហ្នឹងចាក់ទឹកពេញៗ ទៅដាក់បបរបានទៅគេគួសដួងម៉ឹងឲ្យយើងទៅហូបកន្លែងគេហ្នឹង ។

ប៊ុនថន: បាទ ។

សារ៉េត: មិនឲ្យយើងមកផ្ទះទេ ។

ប៊ុនថន: តែហូបគ្រប់ទេ កាលនៅភូមិ?

សារ៉េត: វាហូបគ្រប់គ្រាន់និងឯង តែគ្រាន់តែថារបស់នោះវាមិនគួរតែធ្វើចុះណាស់ ឧទាហរណ៍ថាគេឲ្យម្នាក់មួយកំប៉ុងសម្រាប់មួយពេល វាយកកន្ទះកំប៉ុងទៅដាក់ជាបបរវាទៅជារាវ ។

ប៊ុនថន: បាទ ។

សារ៉េត: ម្ល៉ោះហើយពេលដែលយើងហូបបបរវាមានការហេវហត់វាធ្វើការមិនពេញកំលាំង ។

ប៊ុនថន: បាទ ។

សារ៉េត: តែប៉ុណ្ណោះចេះតែរស់បានទៅ កុំតែគេសម្លាប់ចោលតែប៉ុណ្ណឹង ។

ប៊ុនថន: តែប្រធានភូមិប្រធានឃុំគាត់នៅចាស់ៗដដែលទេ?

សារ៉េត: កន្លែងខ្ញុំហ្នឹងដូចជាវាសនាល្អរបស់គាត់ដែលប្រធានឃុំហ្នឹងណាស់ ។

ប៊ុនថន: បាទ ។

សារ៉េត: គាត់ធ្វើមេឃុំតាំងពីសម័យសាធារណរដ្ឋមកដល់សម័យប៉ុល ពតចូលហ្នឹងគាត់អស់សិទ្ធជាមេឃុំហើយ ហើយមេភូមិក៏ដូចគ្នាអស់សិទ្ធពីមេភូមិ គេទៅយកមនុស្សដែលល្ងង់មិនដឹងអក្សរមួយតួឲ្យដឹកនាំធ្វើជាកម្មាភិបាលភូមិសម័យហ្នឹង ។

ប៊ុនថន: បាទ ។

សារ៉េត: គេហៅថាកម្មាភិបាលភូមិដឹកនាំភូមិហើយថ្នាក់មេឃុំជំនាន់ហ្នឹង តា រៀមហ្នឹងគាត់ធ្វើមេឃុំហើយគាត់ក៏មិនស្លាប់ គាត់រស់នៅបានរហូតមក ។

ប៊ុនថន: បាទ ។

សារ៉េត: ដល់ពេលមកស្លាប់ ស្លាប់សម័យ៩៦-៩៧នេះ ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ គេតែងតាំងគាត់ឲ្យធ្វើមេឃុំទៀត ពេលដែលយួនចូលមកដល់ស្រុកខ្មែរក្លាមគេតែងតាំងគាត់ឲ្យធ្វើជាមេឃុំដល់ពេលហ្នឹងគាត់ប្រកែក គាត់ថាគាត់មិនធ្វើដល់នេះគាត់ឲ្យមេស៊ុយគ្រានជំនាន់ពួកខ្ញុំជំនាន់ឆ្នាំ៧៣-៧៤ហ្នឹង គាត់និងធ្វើជាមេស៊ុយគ្រានដល់មកសម័យប៉ុល ពត គាត់និងទៅជាប្រធានការដ្ឋាន គាត់និងដូចជាវាសនាគាត់ល្អដែរ ខ្មែរក្រហមរកតែមុខគាត់ថាឲ្យតែឃើញសម្លាប់ចោល ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ ដល់ពេលដែលជួបហើយគ្រាន់តែកោត្រសៅ្វលលែងទៅវិញឲ្យគាត់ធ្វើជាប្រធានការដ្ឋាន ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ ធ្វើប្រធានការដ្ឋានគាត់ធ្វើការនៅក្នុងភូមិហ្នឹងប្រជាពលរដ្ឋស្អប់គាត់គ្រប់គ្នាថា ហ៊ានតែប្រែក្រឡាស់ទៅវិញ គេនិងប្ដឹងឲ្យយកទៅជាកលគុកសម្លាប់ចោលដើម្បីឲ្យគេរួចកំហឹង ទឹងគាត់ហ្នឹង ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ ដល់ពេលហ្នឹងយួនចូលមកគាត់បានធ្វើជាមេភូមិហើយធ្វើជាមេឃុំទៀត ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ ហ្នឹងឈ្មោះ គនហ្នឹង ដល់ឈ្មោះគនគេទម្លាក់ចោលឈប់ឲ្យធ្វើជាមេឃុំនេះឡើងមេឃុំរៀមពីសម័យលន់ នល់នោះហើយសម័យរដ្ឋប្រហា ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ ដល់គាត់ធ្វើជាមេឃុំគាត់ដឹកនាំកសាងទៅវាមានការរីកចំរើន តែដល់ខ្មែរក្រហមវាចូលម្នាក់ពីរនាក់មកវាមកបាញ់មេឃុំនោះហើយចោល មេឃុំរៀមហ្នឹង ។

ប៊ុនថន៖ មេឃុំរៀម?

សារ៉េត៖ បាទ!កូនគាត់ពួកម៉ាក់ខ្ញុំនិងឈ្មោះ អា សារូគាត់និងឈ្មោះរៀមដល់ពេលពួកម៉ាក់ខ្ញុំនិងវាធ្វើជាមេប៉ូលីសប្រចាំឃុំនិងឯង ចូលមកបាញ់ទាំងកូនបាញ់ទាំងឪចោលនិងខ្មែរក្រហម ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ បាញ់ក្នុងមន្ទីរវត្តកំពង់តែធ្វើបុណ្យឆ្លងសាលាឆាន់ស្លាប់ពេលនោះទៅ ។

ប៊ុនថន៖ ចឹងកាលហ្នឹងនៅមានបុណ្យដែលពូ?

សារ៉េត៖ បុណ្យនោះបុណ្យសម័យយើងគណបក្សប្រជាជនកាន់កាប់ហើយ ។

ប៊ុនថន៖	បាទ ។

សារ៉េត៖	ឆ្នាំ៨៧-៨៨នេះអេះ!ឆ្នាំ៩៧-៩៨ ។

ប៊ុនថន៖	យ៉ាងម៉េចបានជាបាញ់គាត់ ដោយសារតំនុំប្តូមួយយ៉ាងម៉េច?

សារ៉េត៖	ខ្មែរក្រហមពីខាងយើងបាត់ដំបងវាខុសពីខ្មែរក្រហមខាងយើងខាងនេះ ខ្មែរក្រហមនៅស្រុកភូមិនេះខ្ញុំមកនៅកន្លែងនេះ ខ្ញុំឃើញខ្មែរក្រហមដើរលេងស្ពាយកាំភ្លើងក្នុងភូមិបាន ។

ប៊ុនថន៖	បាទ ។

សារ៉េត៖	បើខ្មែរក្រហមនៅភូមិខ្ញុំនោះហ៊ានតែចូលភ្ជាមអ្នកភូមិអុចទាហានឲ្យដេញបាញ់ហ៊ុយដីទ្រលោមដល់ពេលហ្នឹងដែលគាត់មានសហគមន៍ពីសហរដ្ឋគេជួយជាលុយជាកាក់មកគាត់កសាងសាលខបដ្ឋាដល់ពេលគាត់ធ្វើសាលាខបដ្ឋារួចគាត់ជាមេឃុំគាត់មានតួនាទីគ្រប់គ្រងទីវត្តនិងដែរ ។

ប៊ុនថន៖	បាទ ។

សារ៉េត៖	ក្នុងឃុំរបស់គាត់ដែរ ។

ប៊ុនថន៖	បាទ ។

សារ៉េត៖	ដល់ពេលហ្នឹងខ្មែរក្រហមយើងកំពង់តែធ្វើបុណ្យមានដាក់ធុងបាស់អីរាំបញ្ចាំងស៊ីឌីអីចឹងទៅល្បែងល្បាំច្រើនទៅវាប្រឡូចូលមកបាញ់តែមេឃុំនិងមេប៉ូលីសហ្នឹង ។

ប៊ុនថន៖	បាទ ។

សារ៉េត៖	បាញ់ចោលតែពីរនាក់ប៉ុណ្ណោះឯង ក្រៅពីនោះវាមិនបានបាញ់វាបាញ់តែពីរនាក់រួចវាទៅវិញបាត់ វាលួចចូលមក ។

ប៊ុនថន៖	បាទ ។

សារ៉េត៖	យើងការពារវាមិនបាន ព្រោះមនុស្សវាច្រើនវាប្រឡូខ្លួនចូល គាត់ក៏ស្លាប់ពេលនោះទៅ ។

ប៊ុនថន៖	តែពីមុនមកគាត់នៅរហូត?

សារ៉េត៖	ពីមុនមកគាត់បានសុខរហូតមក ។

ប៊ុនថន៖	ចឹងមូលហេតុអីនិយាយថាគេមិនធ្វើអីគាត់?

សារ៉េត៖	ព្រោះក្នុងភូមិហ្នឹងគេសហករណ៍គ្នាល្អណាស់ ។

ប៊ុនថន៖	បាទ ។

សារ៉េត៖	ដូចថាគេសាមគ្គីគ្នាជិតស្និទ្ធគេធ្វើយ៉ាងណាមិនឲ្យស្លាប់មនុស្សក្នុងភូមិគេ ។

ប៊ុនថន៖	បាទ ។

សារ៉េតៈ តែមានស្លាប់មនុស្សម្នាក់ពីរនាក់នោះអាសម័យនោះវាយកអ្នកលួង់ដឹកនាំហើយវាមានគំនុំបុគ្គលណាស់ ។

ប៊ុនថន: បាទ ។

សារ៉េតៈ ពាក្យសម្ដីបន្ដិចបន្តួចចឹងទៅមានការទឹងចឹងទៅវាយការណ៍ថាអ្នកហ្នឹងទៅចាប់មាន់លួចស៊ីក៏ទៅលួចអង្ករដាំបាយចឹងទៅ ពួកហ្នឹងត្រឹមតែប៉ុណ្ណោះវាចាប់យកទៅបាញ់ចោលហើយ ។

ប៊ុនថន: បាទ ។

សារ៉េតៈ រឿងវាតែប៉ុណ្ណឹងឯង ។

ប៊ុនថន: ចឹងគណៈស្រុកអីគាត់នៅផ្លាស់ផ្ដូរទេ?

សារ៉េតៈ មេស្រុកជំនាន់ប៉ុល ពត ។

ប៊ុនថន: បាទ ។

សារ៉េតៈ មេស្រុកជំនាន់ប៉ុល ពតដែកខ្ញុំនៅចល័តចុះមិនបានស្គាល់ទេ ព្រោះអីកាលនៅចល័តនិងបើនិយាយឲ្យឃើញទៅបើភ្នែកឡើងឃើញដីកតែដី ។

ប៊ុនថន: បាទ ។

សារ៉េតៈ បើគេឲ្យសួងដកបើកភ្នែកឡើងសួងដក មានតែសួងយប់ទៀតដងដាក់ភ្លើងម៉ាស៊ីនសួងយប់វេទនាអារឿងធ្វើការយប់ ។

ប៊ុនថន: ធ្វើការយប់ធ្វើទាំងអស់គ្នា?

សារ៉េតៈ បើប្រជាជនគេនៅតាមមូលដ្ឋាន គេមិនធ្វើទេ គេធ្វើសម្រាប់តែពួកខ្ញុំកន្លែងហ្នឹងភ្នំប៉ារដេ ។

ប៊ុនថន: បាទ ។

សារ៉េតៈ គេហៅភ្នំប៉ារដេនៅខាងត្បូងបាត់ដំបង កន្លែងគេថាសមរភូមិក្ដៅ ។

ប៊ុនថន: បាទ ។

សារ៉េតៈ មនុស្សគេយកមកពីភ្នំពេញរាប់ម៉ឺននាក់ គេយកមកទុកនៅកន្លែងហ្នឹងហើយគេប្រើនោះបើតាមការស្មានរបស់ខ្ញុំទៅ គេប្រើនិងជានយោបាយត្រជាក់សម្លាប់មនុស្សដោយមិនលំបាកវ៉ៃ ។

ប៊ុនថន: បាទ ។

សារ៉េតៈ ព្រោះគេឲ្យយើងហូបបាយតែមួយចុបប៉ុននេះទេ គេបបរនិងល្ងបតែយើងចូកទៅជាប់មិនមែនបបររាវទេ បើយើងនិយាយទៅថាបាយឈ្មោះ ។

ប៊ុនថន: បាទ ។

សារ៉េតៈ	កូនកាគេតូចអើយតូចគេចូកហើយគេគោះខ្ទុកៗ ចេញមកចំនួនមួយកំប៉ុងនោះហើយដែលយើងបានហូបប្រហែលចំនួនមួយកំប៉ុងនោះហើយ តែពួកកងចល័តស្រីៗ ត្រឹមម៉ោង១២ព្រឹក គេបានបាយព្រឹកហើយ ដល់ពួកខ្ញុំម៉ោង៣បានបាយព្រឹក ។

ប៊ុនថនៈ	ហើយយ៉ាងម៉េចបានខុសគ្នាចឹង?

សារ៉េតៈ	មនុស្សច្រើនហើយឆ្នាំងខ្ទះវានិងមានតែ៧ខ្ទះទេ វាយកខ្ទះតែ៧ទេសម្រាប់ធ្វើបបរហ្នឹងដាំស្ងួណាស់ ហើយមនុស្សនិងមាន៧០០០នាក់នៅកន្លែងហ្នឹង ។

ប៊ុនថនៈ	បាទ ។

សារ៉េតៈ	តែវារួមពួកខ្ញុំទៅជាមួយវាមានតែ១៥នាក់ទេ ក្រៅពីនោះសុទ្ធតែពួកមកពីភ្នំពេញមកពីខេត្តផ្សេងៗ គេយកមកទុកនៅហ្នឹង ចឹងបានថាគេសម្លាប់រឿងនេះជានយោបាយត្រជាក់នេះបានជាខ្ញុំហ៊ានថាជានយោបាយត្រជាក់ គេអត់មានចាប់យើងទៅវ៉ៃទៅគប់ឬយកយើងទៅដាក់គុកវ៉ៃដុំប្រាំធាក់អីទេ ។

ប៊ុនថនៈ	បាទ ។

សារ៉េតៈ	គេឲ្យយើងហូបតិចតែឲ្យយើងធ្វើការច្រើន ដើម្បីថាដូចជាខ្ញុំដើរចឹងទៅ គេដើរពីមុខខ្ញុំនិងបើគេដួលព្រោះខ្ញុំត្រូវតែលើកគេ បើខ្ញុំមិនលើកគេខ្ញុំចង់ពិសោធន៍មើល ខ្ញុំពិសោធន៍មើលតែមិនមែនតែសម្រាប់ខ្ញុំទាំង១៥អ្នកនិងទេណាស់ ។

ប៊ុនថនៈ	បាទ ។

សារ៉េតៈ	សម្រាប់តែអ្នកភ្នំពេញនិងអ្នកខេត្តនានាហ្នឹង កាលណាគាត់ដើរតាមភ្លឺស្រែហ្នឹងតែគាត់ដួលហើយថ្ងៃឡើងម៉ោង១១ដែលខ្ញុំឡើងពីស្ទូងមកវិញងាប់នៅហ្នឹង ដួលយ៉ាងណាគឺនៅយ៉ាងនោះអត់មានប្រែខ្លួនរួចទេ ព្រោះវាស្គមអស់រលីងហើយ ។

ប៊ុនថនៈ	បាទ ។

សារ៉េតៈ	នៅតែស្បែកនិងឆ្អឹងទេ តែគ្នាចេះតែទៅទាំងនោះឯងម៉ោង៣រៀបព្រឹកវាផ្ទុកាចែហើយវាដើរវ៉ៃ នរណាឈឺនរណាជា បើនិយាយទៅអ្នកជាអត់មានទេ មានតែអ្នកឈឺទាំងអស់ ។

ប៊ុនថនៈ	បាទ ។

សារ៉េតៈ	វាឈឺនិងសន្តិអារម្មណ៍វាឈឺទាំងកំលាំងកាយឈឺទាំងខ្លួនប្រាណទាំងអស់ ម្លោះហើយគ្នាទៅដោយបង្ខំចិត្តទៅដួលត្រង់ណាងាប់ត្រង់ហ្នឹង ខ្ទះណានៅវានឿនខ្លាំងទៅវាដើរទៅស្ទូងចឹងឡើងដេកនិងដំបូកងាប់និងដំបូងនិងទៅ ។

ប៊ុនថនៈ	បាទ ។

សារ៉េតៈ ចឹងបានថាវាសម្លាប់សម័យនោះវាសម្លាប់របៀបនិងឯង តែខ្ញុំគេយកបានទៅតែ៧ខែគេលត់ដុំខ្ញុំខ្លាំងខ្ញុំរត់មកវិញ ។

ប៊ុនថន: បាទ ។

សារ៉េតៈ ខ្ញុំរត់វាតាមៗបីដងបួនដង លើកនេះខ្ញុំអត់មកផ្ទះទេខ្ញុំរត់បានខ្ញុំទៅសុំពេទ្យ កាលហ្នឹងគេមានមន្ទីរពេទ្យបដិវត្តនិងគេសម្រាប់ព្យាបាលអ្នកជំងឺ ខ្ញុំមនុស្សក្នុងឃុំនោះវាមិនដែលមនុស្សស្គមប៉ុនរូបខ្ញុំទេ ។

ប៊ុនថន: បាទ ។

សារ៉េតៈ ដែលខ្ញុំ១៥នាក់និងគឺស្គមខ្លាំងហើយរត់មកវិញអត់រួចទេ រត់មកវិញបានតែ៦នាក់ទេ អា៩នាក់នោះមិនដឹងជាមុខមាត់ទៅខាងណាទេ ។ វាចាប់បានទៅវិញខ្លះខ្ញុំរត់មកខ្ញុំទៅចូលពេទ្យចូលពេទ្យដល់ពេលហ្នឹងវាមកតាម វាតាមមកសុំវាមកសុំខ្ញុំថាអត់ទៅទេ ខ្ញុំទៅមិនរួចដល់នេះវាទៅសុំពេទ្យ ទៅសុំពេទ្យ ពេទ្យថាឲ្យទៅសុំមេឃុំទៅ ។ កាលនោះគេមានគណៈឃុំ ។

ប៊ុនថន: បាទ ។

សារ៉េតៈ គាត់មានឈ្មោះមេឃុំរិន ។

ប៊ុនថន: មិនមែនមេឃុំដដែលទេពូ?

សារ៉េតៈ មិនមែនឃុំរៀមទេអាហ្នឹងឃុំរិន មេឃុំជំនាន់ប៉ុល ពត ។

ប៊ុនថន: បាទ ។

សារ៉េតៈ ដែលមេឃុំរៀមនោះអាហ្នឹងមេឃុំសម័យគណបក្សប្រជាជន ។

ប៊ុនថន: បាទ ។

សារ៉េតៈ ដល់ពេលហ្នឹងមេឃុំហ្នឹងគាត់ថាមិនឲ្យទេ បើចង់បានកំលាំងមានច្រើនគាត់ឲ្យក៏វាថាបើមិនបានកំលាំងដែលរត់មកយកទៅវិញទេ វាអត់យកដល់ពេលហ្នឹងគាត់ថាបើមិនយកទេហីទៅគាត់មិនចង់ឲ្យទៅដែលយកមនុស្សគាត់ទៅធ្វើឲ្យស្គមអត់រលីងចឹង ។ ហើយមនុស្សនៅក្នុងឃុំគាត់ហ្នឹងគាត់រក្សាល្អណាស់ ដូចខ្ញុំនិយាយចឹង ។

ប៊ុនថន: បាទ ។

សារ៉េតៈ សូម្បីតែទាហានហើយមិនបានស្លាប់នៅសម័យនោះទេ ។

ប៊ុនថន: បាទ ។

សារ៉េតៈ ដល់ពេលហ្នឹងគាត់មិនឲ្យទៅ គាត់មិនឲ្យទៅវាប្រឆាំងវារឹងរូសដល់នេះវាថាមកពីពេទ្យមកពីមេឃុំហ្នឹងឯងយកមនុស្សប៉ុន្មាននាក់ទៅវិញមិនបាន ។ ដល់នេះវាដើរទៅប្រាប់ពេទ្យថាបង

ពេទ្យឯងកោសខ្យល់ខ្ញុំបន្តិចមក  ពេទ្យប្រាប់ថាអង្គុយខាងក្រៅទៅចាំខ្ញុំផ្លាស់សំពត់សម្លៀកបំពាក់រួចខ្ញុំកោសឲ្យ ។  ដល់ពេលហ្នឹងវាធាក់ទ្វារជាំងវាដើរចូលទៅយកកាំបិតទៅដេញចាក់ពេទ្យ  គ្រាន់ប្រើឲ្យកោសខ្យល់ប៉ុណ្ណឹងមិនបាន  ពេទ្យនោះក៏គាត់ស្រែកបងរើនអើយៗបងរើនហ្នឹងគាត់ជាអ្នកការពារពេទ្យ ។  ថាបងរើនអើយគាត់ដេញចាក់ខ្ញុំចឹងដល់នេះហៅវាចេញមកវិញមកឈ្មោះវា  អាឆយមិត្តឆយចេញមកវិញមកដល់ចេញមកវិញវាអង្គុយតុបដល់ពេលហ្នឹងពេទ្យផ្លាស់ខោអាវរួចថាប្រុងមកកោសខ្យល់ឲ្យវា  វាដើរព្រុយទៅពេទ្យហ្នឹងចូលក្នុងបន្ទប់វាដើរមកវិញ  មកដល់កាំបិតវាពីរសៀតខាងនេះមួយខាងនោះមួយវាដកមកវាចោលជញ្ជាំង  ជញ្ជាំងយើងធ្វើពីស្លឹកដូងធ្វើជាក្រឡាការ៉ូ ។

ប៊ុនថន: បាទ ។

សារ៉េត: វាយកកាំបិតហ្នឹងចោលជាប់ខាងនេះមួយខាងនោះមួយពេទ្យនារីគាត់ស្រែកថាបងរើនអើយមកធ្វើយ៉ាងចេះងាប់ហើយខ្ញុំ  ដល់នេះអារើនហ្នឹងអាកងការពារពេទ្យហ្នឹងវាទៅដល់វាធាក់មួយជើងធាក់បានវាចាប់ចងយកទៅវៃវា  អាហ្នឹងខ្មែរក្រហមវៃខ្មែរក្រហមហើយ ។

ប៊ុនថន: បាទ ។

សារ៉េត: ដល់វៃៗវាមិនងាប់មិនដឹងគិតធ្វើម៉េចចាប់ចងវៃហើយវៃវាមិនបានងាប់ដាក់ប្រេកបាវដាក់ដុំថ្មពន្លិចទឹកបានងាប់ ។

ប៊ុនថន: កាលហ្នឹងពូរត់ពីការដ្ឋានណាវិញ?

សារ៉េត: រត់ពីកន្លែងគេហៅស្វាយស  ស្វាយសខាងជើងឈៀងខាងលិចភ្នំប៉ាដេ ។

ប៊ុនថន: បាទ ។

សារ៉េត: អាហ្នឹងសមរភូមិក្ដៅគេហើយអាហ្នឹង ។

ប៊ុនថន: ចឹងអ្នកដែលមកតាមពូហ្នឹងស្លាប់?

សារ៉េត: បាទ!ស្លាប់ពេលហ្នឹង ។

ប៊ុនថន: តែអត់មានហេតុការណ៍កើតឡើងទៀតទេ?

សារ៉េត: អត់មានហេតុការណ៍អីទេ  សម្លាប់ចោលហើយរាយការណ៍ទៅឲ្យតំបន់គេទៅប្រាប់ថាមនុស្សហ្នឹងស្លាប់ហើយឲ្យគេត្រឡប់ទៅវិញគេមិនទៅហើយគេចង់ធ្វើឃាដពេទ្យ ។  វានិយាយទៅវាចង់សុំរូបខ្ញុំនេះហើយ  បើសុំវាមិនបានបើមិនបានឲ្យទាំងអស់វាសុំតែរូបខ្ញុំម្នាក់ ។

ប៊ុនថន: បាទ ។

សារ៉េត: យកទៅដើរទៅតាមផ្លូវមានការនឿយហត់វាសម្លាប់យកថ្លើមស៊ីវាថាចឹង ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ ដល់ចឹងគេថាសម្លាប់វាចោលមួយទៅ ព្រោះមួយហ្នឹងធ្វើឲ្យគេស្លាប់ច្រើន ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ ព្រោះវាហ្នឹងបញ្ហាការសមរភូមិក្តៅហ្នឹងហើយវាយកគេទៅសម្លាប់អស់ច្រើន វាមិនមែនសម្លាប់ទេ វាសម្លាប់ដូចខ្ញុំថាចឹងដោយមានការហត់ហេវអត់បាយអត់ទឹកចឹងទៅ យប់មិនបានដេក យប់ដូចពួកខ្ញុំវាយកទៅហ្នឹងម៉ោង៣ល្ងាចបានបាយព្រឹក ម៉ោង៦ល្ងាចបានបាយល្ងាច ដល់ពេលបាយរួចម៉ោង១១យប់បានឲ្យមកដេក ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ ហើយម៉ោង៣វាដាស់ទៅវិញហើយ មិនបានដេកពួនអីប៉ុន្មានទេ ។

ប៊ុនថន៖ ចឹងមានអ្នកស្លាប់ច្រើនទេកន្លែងហ្នឹង?

សារ៉េត៖ កន្លែងហ្នឹងស្លាប់ច្រើន ស្លាប់សឹងថារាប់ពាន់នាក់ក៏ថាបាន ព្រោះដើរទៅដំបូកណាក៏មានខ្មោចអត់មានកប់ទេ បើថាដេកពីរនាក់ស្លាប់ទាំងពីរហ្នឹងឡើងក្រៀមកាំពិតនៅហ្នឹង ដែលដួលតាមភ្លឺស្រែដែលដើរទៅស្លាប់ត្រង់ណាហើមចោលត្រង់នោះឯង ។

ប៊ុនថន៖ ចឹងអត់មានពីណាយកទៅកប់ទេ?

សារ៉េត៖ អត់មានពីណាយកទៅទេ យកទៅកប់យកទៅអីណាទេ ។

ប៊ុនថន៖ ស្លាប់ហ្នឹងភាគច្រើនអ្នកថ្មីឬមួយអ្នកចាស់ពូ?

សារ៉េត៖ សម្បូរអ្នកមកពីខាងភ្នំពេញ ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ បើអ្នកនៅតំបន់នោះគេ គេនៅជាមូលដ្ឋានរបស់គេវាមិនអីទេ ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ ដែលស្លាប់និងស្លាប់ចំពោះតែចល័តដែលគេដកចេញពីម៉ែពីឪមកគេយកមកគ្រប់គ្រងដោយខ្លួនគេផ្ទាល់ ។

ប៊ុនថន៖ តំបន់ហ្នឹងចូលតំបន់ប៉ុន្មានហើយពូ?

សារ៉េត៖ កាលហ្នឹងមិនដឹងជាតំបន់ប៉ុន្មានទេ កាលហ្នឹងបែបចូលតំបន់៣កាលហ្នឹង ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ តំបន់១ដឹង តំបន់១តែសង្កែលើក្នុងស្រុកសង្កែលើ ។

ប៊ុនថន៖ តំបន់១?

សារ៉េតៈ បាទ ។

ប៊ុនថន: ពីណាជាគណៈតំបន់កាលហ្នឹង?

សារ៉េតៈ គណៈតំបន់ហ្នឹងមិនដឹងឈ្មោះអីដែរ ព្រោះកាលសម័យហ្នឹងមិនសូវជាបានយកចិត្តទុកដាក់ស្គាល់ ។

ប៊ុនថន: បាទ ។

សារ៉េតៈ ស្គាល់តែមេដឹកនាំកំពូលទាបៗទេ បើអាកំពូលខ្ពស់ៗខ្ញុំអត់បានស្គាល់ទេ ខ្ញុំតែងតែឮគេនិយាយថា គណៈតំបន់ឈ្មោះគាត់ តា វ៉ាញ់ចេះឯង ។

ប៊ុនថន: តា វ៉ាញ់?

សារ៉េតៈ បាទ!ឈ្មោះ តា វ៉ាញ់ ព្រោះមេដឹកនាំធំៗហ្នឹងមានឈ្មោះតា វ៉ាញ់ ឈ្មោះ តា ប៉ែត ឈ្មោះ តា ញឹម ឈ្មោះ តា កៅមានឈ្មោះបួនតែមិនដឹងមួយណាកាន់មុខក្រសួងខាងអីខ្ញុំមិនបានដឹង ។

ប៊ុនថន: បាទ ។

សារ៉េតៈ តែអ្នកទាំងបួននេះឯងជាអ្នកដឹកនាំនៅក្នុងតំបន់នោះ ។

ប៊ុនថន: បាទ!ចុះគាត់ជាអ្នកមកពីណាដែរ?

សារ៉េតៈ តា ប៉ែត តា កៅនេះបើនិយាយទៅគាត់មិនមែនឈ្មោះ តា ប៉ែត តា កៅទេ គាត់ឈ្មោះ ចំរើនចេះអី មួយទៀតនោះឈ្មោះ ប៉ាយ៉ៃទីវ១ ព្រោះគាត់ពីដើមគាត់ធ្វើប៉ាយ៉ៃសម័យថៃចូលស្រុកនោះ ថៃចូលស្រុកខ្មែរយើងឆ្នាំប៉ុន្មាន ។

ប៊ុនថន: ឆ្នាំ៤០ជាង ។

សារ៉េតៈ នោះហើយគាត់ហ្នឹងគាត់ធ្វើប៉ាយ៉ៃភូមិបើខ្មែរយើងថាប្រធានភូមិ ។

ប៊ុនថន: បាទ ។

សារ៉េតៈ ប៉ាយ៉ៃហ្នឹងប្រធានភូមិអីណាម៉ែវ៉ា គេហៅគាត់ថាប៉ាយ៉ៃទីវដល់ឈ្មោះពិតប្រាដខ្ញុំអត់ដឹងទេគេហៅប៉ាយ៉ៃទីវឈ្មោះដើមគាត់ ។

ប៊ុនថន: បាទ ។

សារ៉េតៈ មួយទៀតហ្នឹងឈ្មោះចំរើន ដល់ពេលគាត់ចេញតស៊ូឆ្នាំ៦០គត់ ឆ្នាំ១៩៦០ គាត់ទៅតស៊ូប្រឆាំងជាមួយសង្គមរាស្ត្រនិយម ។

ប៊ុនថន: បាទ ។

សារ៉េតៈ ដល់ពេលហ្នឹងសម្តេចឪសម្តេចតាយើងនេះ លោកបង្កើតជាក្រុមប៉ូលីសឲ្យនៅការពារភូមិ ដល់ពេលហ្នឹងប៉ូលីសគេដឹងថា អ្នកទាំងពីរហ្នឹងចេញតស៊ូប្រឆាំងរបបគេ គេបន្លាញឈ្មោះ ថា ឈ្មោះ ប៉ាយ៉ៃទីវនេះនិងចំរើននេះ បើរកឃើញឲ្យអ្នកស្រុកចាប់ចងមកឲ្យគេ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ ប៉ូលីសនិងគេឲ្យបើវាឆ្ងាយចាប់មិនបានទេ ដេញវ៉ៃធ្វើម៉េចបានស្លាប់កាត់តែក្បាលយកមក ឲ្យគេក៏គេយកដែរ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ ក្នុងក្បាលមួយៗគេឲ្យ៨០ម៉ឺននិង៩០ម៉ឺនចេះ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ ដល់នេះគាត់ចូលមកដល់ឆ្នាំ៧៥ ពេលដែលយើងឯករាជ្យខ្មែរក្រហមហ្នឹង ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ សម័យបីឆ្នាំហ្នឹងណាស់ កាលដែលគាត់ចូលមកដល់គាត់និងគាត់ដើរបន្លាញថា កុំឲ្យហៅគាត់ ទីវកុំឲ្យហៅគាត់ចំរើនអី ឲ្យហៅថាតា ប៉ែតៗទៅព្រោះក្បាលគាត់មួយគេឲ្យតម្លៃ៨០ម៉ឺន ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ គាត់ដាក់នាមគាត់ឈ្មោះថា ប៉ែតចេះ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ ៨០ម៉ឺនហ្នឹង ដូច្នេះគេហៅគាត់តា ប៉ែតៗទៅដល់មួយទៀតនោះគេឲ្យ៩០ម៉ឺន ព្រោះមួយ ទៀតនោះគេប្រធាន ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ អនុប្រធាននោះគេឲ្យ៨០ម៉ឺនប្រធាននោះគេឲ្យ៩០ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ បានគេឲ្យឈ្មោះថា តា ប៉ែតនិង តា កៅ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ ចឹងពេលហ្នឹងគាត់បានតស៊ូមុនគេបានសម្រេចនិងបានគេតែងតាំងគាត់ឲ្យធ្វើមេតំបន់ហ្នឹងឯង ទៅ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ តំបន់១ ។

ប៊ុនថន៖	តបន់១?

សារ៉េត៖	បាទ!តែតំបន់គេខ្ទីកំលាំងខ្ញុំ ខ្ញុំនៅតំបន់ទី១តែគេខ្ទីកំលាំងខ្ញុំ ខ្ញុំនិយាយថា១៥នាក់នោះគេខ្ទីយកទៅតំបន់ហ្នឹងប្រហែលជាតំបន់៣ តែនៅក្នុងស្រុកសង្កែលើ ។

ប៊ុនថន៖	បាទ ។

សារ៉េត៖	នៅជិតភ្នំប៉ារដេហ្នឹងឯង ។

ប៊ុនថន៖	ចឹងកាលហ្នឹងគេអាចសុំកំលាំងពីតំបន់មួយទៅតំបន់មួយបានតែដែរ?

សារ៉េត៖	បាទ!គេសុំស្នើទៅជួយតែនៅពេលទៅជួយនិងមិនមែនជួយបង្កបង្កើនផលស្របច្បាប់ទេ សមរភូមិក្តៅហ្នឹងគេយកសម្រាប់ធ្វើនយោបាយត្រជាក់សម្រាប់សម្លាប់យើងតែម្តង ។

ប៊ុនថន៖	បាទ ។

សារ៉េត៖	ព្រោះអីគ្នា៧០០០នាក់ អាត្រាក់៧គ្រឿងឲ្យធ្វើការអត់មានពេលទំនេរសោះ អត់មានថ្ងៃអាទិត្យទេ ។

ប៊ុនថន៖	អាត្រាក់ជីកដី?

សារ៉េត៖	អត់មានជីកដីទេ ឲ្យស្ទូងឲ្យដកតែតំបន់នោះវាព្រៃរាប់រយហិចតា ។

ប៊ុនថន៖	បាទ ។

សារ៉េត៖	ហើយអត់មានភ្លឺស្រែទេ ដីស្មោយើងធម្មតាហ្នឹង តែគេហៅថាតំបន់ជាកន្លែងបរិស្ថាន ។

ប៊ុនថន៖	បាទ ។

សារ៉េត៖	គេថែរក្សាបរិស្ថានទុកព្រៃឈើ សម័យនិងគេអត់គិតប៉ះពាល់រឿងបរិស្ថានទេ វាគិតពីរឿងបង្កបង្កើនផល ។

ប៊ុនថន៖	បាទ ។

សារ៉េត៖	ដូច្នេះវាអត់មានកាប់ឈើមួយដើមទេ វាគ្រាន់តែដាក់ អាត្រាក់យើងវាដាក់ដើងដែកដូចដើងគោយន្តចឹង ។

ប៊ុនថន៖	បាទ ។

សារ៉េត៖	អានេះដើងកៅស៊ូធំរបស់វា ហើយវាតដើងដែកមកខាងនេះភ្ជាប់មកដើងកៅស៊ូ ។

ប៊ុនថន៖	បាទ ។

សារ៉េត៖	វាបរពាវវាដាក់ទ្រនាប់ពីក្រោយចឹងទៅវាបរពាវៗឲ្យវារៀបស្មើឲ្យយើងស្ទូងតាម មនុស្សណាបានស្ទូងទាន់អាត្រាក់ អាត្រាក់វាបរវ៉ូតំរៀបគ្នាទៅចឹងឲ្យស្ទូងឲ្យទាន់ ។

ប៊ុនថន៖	បាទ ។

សារ៉េតៈ ឲ្យស្ទួងវាធ្វើវង់ៗឲ្យល្អិតម៉ាព្រៃចឹងវាចេញចូលព្រៃខាងនោះស្ទួងខាងនោះទាន់វាទៅព្រៃខាងនោះទៀតចេះតែទៅៗហើយយប់ឡើងយើងសម្រាកគ្នាវា វាផ្លាស់ផ្លូ តា កុង វាកិនដីវាស់ព្រឹកហើយយើងចេះតែស្ទួងតាមវាទៅ ថាក្នុងមួយថ្ងៃបើនិយាយពីពេលសម្រាកអត់មានទេ ។ ចាប់ពីម៉ោងបីព្រឹករៀបភ្លឺដល់គ្នាម៉ោង១១យប់ ។

ប៊ុនថន: បាទ ។

សារ៉េតៈ អត់មានពេលសម្រាកទេ មានតែពេលមកហូបបាយមួយភ្លេតអង្គុយចាំពេលបាយនិងមួយភ្លេតរួចហើយចុះទៅទៀតបាត់ វាអត់មានម៉ោងសម្រាកទេ បានជាមនុស្សចុះស្គមកំលាំងល្ហិតល្ហៃស្លាប់ដោយមិនពិបាកសម្លាប់ ។

ប៊ុនថន: បាទ!ចឹងកាលពូមកនៅមន្ទីរពេទ្យហ្នឹងស្នាក់នៅយូរទេ?

សារ៉េតៈ ខ្ញុំមកស្នាក់នៅបានតែបីថ្ងៃ នៅពេលដែលគេសម្លាប់វាចោលចេញទៅខ្ញុំមានកើតអីខ្ញុំ ខ្ញុំគ្រាន់ធ្វើជាពុត ។

ប៊ុនថន: បាទ ។

សារ៉េតៈ ព្រោះអី បើយើងមិនធ្វើពុតចឹងត្រូវស្លាប់នៅកន្លែងវា ។

ប៊ុនថន: បាទ ។

សារ៉េតៈ ព្រោះយើងមិនមែននៅក្រោមបញ្ជាតំបន់របស់វាណា យើងនៅតំបន់យើងខាងនេះ ។

ប៊ុនថន: ចឹងពូចេញពីហ្នឹងមកទៅណាទៀតពូ?

សារ៉េតៈ ដល់ខ្ញុំចេញពីមន្ទីរពេទ្យមកខ្ញុំមករស់នៅក្នុងមូលដ្ឋានធម្មតាវិញមក ម៉ែឪឲ្យយកប្រពន្ធ ។

ប៊ុនថន: បាទ ។

សារ៉េតៈ តែមុនយកប្រពន្ធនោះ ខ្ញុំចេញពីហ្នឹងមកខ្ញុំចេញកាលនោះខែ១០ ។

ប៊ុនថន: បាទ ។

សារ៉េតៈ ខ្ញុំចេញពីមន្ទីរពេទ្យហ្នឹងខែ១០ ។

ប៊ុនថន: ឆ្នាំណាពូ?

សារ៉េតៈ ឆ្នាំ៧៧ ។

ប៊ុនថន: បាទ ។

សារ៉េតៈ ខ្ញុំចេញមកខែ១០ ខ្ញុំមកនៅក្នុងភូមិបានដល់ខែ១២គេប្រមូលកំលាំងពួកខ្ញុំនិងឲ្យទៅធ្វើទំនប់កាហតដែលខ្ញុំនិយាយមិញហ្នឹង ។

ប៊ុនថន: បាទ ។

សារ៉េតៈ ធ្វើទំនប់កាហគនិងរហូតដល់គេរៀបចំកំលាំងខាងខ្មែរក្រហមខាងទ័ពពាយ័ព្យនោះ គេបំពាក់ ខោអាវខ្មៅនេះឲ្យ ។ ខោខ្មៅអាវខ្មៅបើទ្រនាប់ជើងមួកឲ្យគេប្រុងគាស់អាវុធយកមកឲ្យពួក ចល័តខ្ញុំហ្នឹងធ្វើការវ៉ៃបកពួកខ្មែរក្រហមចាប់ពីពោធិសាត់ដេញទៅរកភ្នំពេញ ។ តែទទួល គំរោងហ្នឹងវាកើតឡើង គេក៏ចាប់និរសាដែលរត់ការហ្នឹងបានវាបែកការណ៍បានត្រូវគេយក ពួកនិរតីឲ្យមកកាន់កាប់ទឹកដីយើងខាងពាយ័ព្យនេះ ។

ប៊ុនថនៈ បាទ!តែយ៉ាងម៉េចបានពូដឹងថាគេមានគំរោងការណ៍ហ្នឹង?

សារ៉េតៈ យើងដឹងតាមមេកងដែលគេក្តោបក្តាប់យើងនោះ គេនិយាយប្រាប់ហើយមេកងនោះនៅ ពេលនិយាយប្រាប់ឲ្យខ្ញុំដឹងគាត់ក៏មិនបានរស់នៅ គ្រាន់តែគាត់និយាយខ្សិបប្រាប់ពួកខ្ញុំ ហើយ យប់នោះគេចាប់គាត់ ។

ប៊ុនថនៈ គាត់ឈ្មោះអីវិញពូ?

សារ៉េតៈ គាត់ឈ្មោះនី តែខ្ញុំភ្លេចនាមត្រកូលគាត់ហើយ មិនដឹងជាស៊ីនី គាត់នៅភូមិកាញ់ជ្រោង ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ ស្រុកសង្កែ ខេត្តបាត់ដំបង ។

ប៊ុនថនៈ គាត់ជាប្រធានកងពូ?

សារ៉េតៈ គាត់ជាប្រធានកង គាត់កាន់ចល័ត១០០នាក់ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ គាត់និយាយទៅប្រហែលជាមានគិញសម្ងាត់គេណាស់ គេស៊ើបបានដឹងថា គាត់និងដឹងពី គោលការណ៍នយោបាយ ។

ប៊ុនថនៈ ចុះគាត់មាននិយាយច្រើនទេពូ ណែនាំថាគាស់អាវុធអីហ្នឹងគាត់និយាយជុំគ្នាជាមួយកង ចល័តទាំងអស់ឬមួយ?

សារ៉េតៈ អត់ទេ គាត់ហ្នឹងដូចថាខ្ញុំដេកជាមួយគាត់ណាស់ ដេកជាមួយគាត់ថាធ្វើការអីគាត់តែងឲ្យខ្ញុំ ដឹង ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ បើគាត់ទៅណាទៅណី គាត់ឲ្យខ្ញុំដឹងប៉ុន្តែនៅពេលដែលគេចាប់គាត់នោះមិនមានឲ្យខ្ញុំដឹងទេ ខ្ញុំ ដេកលក់គេមកហៅគាត់ស្ងាត់ៗទៅបាត់ ខ្ញុំព្រឹកឡើងដឹងបាត់គាត់ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ	អង្រើងគាត់នៅតែបាត់គាត់ បាត់តែមនុស្សបាត់រហូតដល់ពេលទៅធ្វើការដល់ពេលត្រឡប់មកវិញទៀតបានខ្ញុំចាប់អារម្មណ៍ថា ប្រហែលជាគាត់ដឹងពីគោលការណ៍នយោបាយគេហើយបានត្រូវចឹង ។ ដល់យូរបានមានមេកងស្រីមកនិយាយប្រាប់ខ្ញុំដែរ មេកងខាងនារី ។

ប៊ុនថន: បាទ ។

សារ៉េតៈ	គេថាចៅហ្វាយឯងហ្នឹងគេចាប់យកទៅញាត់គុកនៅបាណន់បាត់ទៅហើយ ដល់ខ្ញុំតាមដានមើលទៅឃើញថាជាប់មែន ដល់សម័យយួនសម័យនិរតីចូលមកកាន់កាប់គេលែងគាត់មកវិញ ។

ប៊ុនថន: បាទ ។

សារ៉េតៈ	មិនបានស្លាប់ទេ គេលែងនិរតីចូលមកគេថាពួកពាយ័ព្យក្បត់ចាប់គ្នាឯងសម្លាប់ចោល ។

ប៊ុនថន: បាទ ។

សារ៉េតៈ	អ្នកដែលនៅគុកទាំងប៉ុន្មានឡេលែងចេញវិញ ដល់ក្រោយមកគេចាប់អ្នកធ្វើការហ្នឹងដាក់គុកសម្លាប់គក្នាវិញទៅតែដដែលហ្នឹង គេគ្រាន់តែមកមុនដិបូងឡេធ្វើល្អអ្នកជាប់គុកគេត្រូវលែងវិញទាំងអស់មិនឲ្យមានសល់ ។

ប៊ុនថន: បាទ ។

សារ៉េតៈ	យកចេញពីគុកទាំងអស់ ។

ប៊ុនថន: ចឹងពេលក្រោយសម្លាប់អ្នកក្នុងគុកនិងវិញដដែល?

សារ៉េតៈ	បាទ!ក្រោយមកវាធ្វើការទៅវាផ្លាស់ផ្តូមុខមេដឹកនាំ ។

ប៊ុនថន: បាទ ។

សារ៉េតៈ	វាផ្លាស់ប្តូមេដឹកនាំវាដាក់គ្នាវាឲ្យដឹកនាំទៅដល់ពេលធ្វើយូរៗវាចាប់យកទៅដាក់ដូចតែគ្នាហ្នឹងឯង ។

ប៊ុនថន: បាទ ។

សារ៉េតៈ	អាហ្នឹងវាគ្រាន់ដូចនិយាយថា ឡានមួយគា កុងពីរនាក់ ។

ប៊ុនថន: បាទ ។

សារ៉េតៈ	គ្រាន់តែយកគា កុងមួយចេញយកគា កុងមួយទៅដាក់តែបរទៅផ្លូវតែមួយវាទៅចឹង ។

ប៊ុនថន: ចឹងនៅពេលនិយាយប្រាប់ពូចឹងពូជឿទេ ថាមានគាស់អាវុធហើយចង់បាស់បោរអីចឹង?

សារ៉េតៈ	ខ្ញុំមានអារម្មណ៍ជឿគាត់ភាគច្រើន ព្រោះអីខ្ញុំសង្កេតឃើញពួកខ្ញុំកាលដែលខ្ញុំនៅចល័តតាមភូមិឃុំ ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ គេមិនដែលមានខោអាវល្អឲ្យស្លៀកទេ ខ្ញុំស្លៀកតែខោអាវធ្វើពីកប្បាសដូចចាស់ៗគាត់ត្បាញតាមកីដូចយើងត្បាញកន្សែងសព្វថ្ងៃហ្នឹង ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ យកទៅក្រណាត់និងសស្លូសដូចក្រណាត់ដូនជីចឹង ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ គេយកទៅយើងប្រលក់ទៅបានខ្មៅប៉ុននេះឯង ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ ជ្រលក់ជាមួយសំបកឈើយកមកពាក់គេមិនឲ្យស្លៀកសទេ ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ ដល់ហើយពេលហ្នឹងខោអាវរវារហ័សផុយណាស់ ដល់ពេលខ្ញុំទៅនៅកន្លែងនោះពេលគាត់និយាយប្រាប់ហើយស្រាប់តែគេបើកខោអាវសាច់ល្អៗមកខ្មៅស្រិលៗ ហើយទ្រនាប់ជើងអីគេមិនឲ្យយើងពាក់អាទ្រនាប់ជើងកាត់កង់ឡានពាក់ដូចពីមុនទេ ។ គេបើកតែម្តងគេហៅទ្រនាប់ជើងកម្ពុជានោះ ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ ទ្រនាប់ជើងនិងគេធ្វើពីកៅស៊ូកង់ឡានដែរ តែគេធ្វើមានពុម្ពចាក់ គេហូតខ្សែស្អាតរបស់គេគេចេញពីរោងចក្រទ្រនាប់ជើងហ្នឹង ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ បានជាខ្ញុំមានអារម្មណ៍ថាទបហែលជាមែនដូចគាត់និយាយ ដល់ពេលហ្នឹងនឹកឃើញភ័យខ្លួនខ្ញុំមិនចង់ធ្វើទ័ពទេ ព្រោះខ្ញុំធ្លាប់ច្បាំងពីក្មេងដែលខ្ញុំធ្វើស៊័យគ្រានដែលខ្ញុំនិយាយហ្នឹង ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ ព្រួសូរក្រាំភ្លើងខ្លាច ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ ម្លោះហើយខ្ញុំមិនចឹងទេ ខ្ញុំមិនចង់ច្បាំងខ្ញុំខ្លាចដែរ ។

ប៊ុនថន៖ ចឹងលោកអាវុធហ្នឹងគាត់មានប្រាប់ថាលាក់នៅណាអីទេ?

សារ៉េត៖ គត់អត់មាននិយាយប្រាប់ថានៅណាទេ គាត់គ្រាន់តែនិយាយថាពួកយើងមិនស្រួលទេបន្តិចប្រទេសជាតិយើងនិងក្រឡាប់ចក្រ ។

ប៊ុនថន: បាទ ៗ

សារ៉េត: ដោយភាគីណាមួយមិនខានហើយ យើងសព្វថ្ងៃនេះ ដែលគេឲ្យ យើងចូលមកជាក្រុមចល័ត តំបន់នេះគេប្រុងយកយើងឲ្យធ្វើទ័ព ៗ ឃើញទេខោអាវសម្លៀកបំពាក់គេផ្លាស់ប្តូឲ្យ យើងឲ្យ អស់អត់មានឲ្យ យើងប្រើរបៀបមុនទេ ៗ ហើយ គេមិនអនុញ្ញាតឲ្យ យើងទៅលេងផ្ទះគេទុក យើងឲ្យនៅតែទីនេះ ថ្ងៃណាមួយ គេនិងប្រគល់អាវុធឲ្យ យើងហើយគាត់និយាយចេះ ៗ

ប៊ុនថន: ចឹងក្រោយពីចាប់គាត់ទៅហ្នឹង កងចល័តពូ ពូអីហ្នឹងមានចាប់ពូបញ្ជូនទៅណាទេ?

សារ៉េត: អត់ទេ គេគ្រាន់តែយកមនុស្សផ្សេងមកឲ្យក្តោបក្តាប់ជាមួយ គេនិយាយថាដល់ពេលបែក ការណ៍ទៅមុនដំបូងគេនិយាយថា មេកងឯងរត់ចោលគេនិយាយចឹង ៗ ដល់ក្រោយគេថា រត់ចោលមកគេថា មេកងឯងគេចាប់ដាក់គុក ៗ

ប៊ុនថន: បាទ ៗ

សារ៉េត: ដល់ខ្ញុំតាមដានទៅឃើញថាជាប់មែន គាត់ជាប់អស់រយៈពេលមួយឆ្នាំ គាត់ជាប់មិនដល់ មួយឆ្នាំទេ គាត់ជាប់ប៉ុន្មានខែស្រាប់តែពួកនិរតីចូលមកគេលែងមកវិញបានខ្ញុំដឹងថា បងនឹង ជាប់គុកមែន ៗ

ប៊ុនថន: តែគាត់មានបានមកជួបពូនិយាយ?

សារ៉េត: គាត់ជួបខ្ញុំដែលតែគាត់មិនបាននិយាយអីទេ គាត់ចេញមកវិញមានការស្មោកស្គាំងស្គមដើរ សឹងមិនរួចក្បាលជង្គង់ធំៗ ៗ

ប៊ុនថន: បាទ ៗ

សារ៉េត: ខ្ញុំគ្រាន់តែឃើញគាត់ចង់ស្រក់ទឹកភ្នែក មិនបាននិយាយកើតហើយគាត់ក៏មិនជួបខ្ញុំយូរ គាត់ ក៏ខ្លាចខ្ញុំ ខ្ញុំក៏ខ្លាចគាត់ដែរ ៗ

ប៊ុនថន: ខ្លាចយ៉ាងម៉េចទៅ?

សារ៉េត: ខ្លាចត្រង់ថាគាត់ជាប់គុកនៅពេលដែលគាត់ចេញពីគុក កាលគាត់និយាយមកឲ្យខ្ញុំឬខ្ញុំនិយាយ ទៅឲ្យគាត់វាទាក់ទងអារឿងគុកហ្នឹងស្រួលមិនៗ គេចាប់ខ្ញុំទៀត ៗ

ប៊ុនថន: បាទ ៗ

សារ៉េត: ស្រួលមិនស្រួលគេយកគាត់ទៅញាត់គុកវិញ សម័យហ្នឹងយើងមិនមានសិទ្ធទេ មានតែសិទ្ធ បាយទឹកធ្វើការតែប៉ុណ្ណោះ ៗ

ប៊ុនថន: បាទ ៗ

សារ៉េតៈ រឿងដើរហើរគ្មានច្បាប់ទម្លាប់ឲ្យដើរទេ គេបិទសិទ្ធសូម្បីផ្ទះគេមិនឲ្យមកខ្ញុំគិតឃើញមិនបាច់នៅយូរទេ រកប្រពន្ធកូនឲ្យហើយទៅដើម្បីបាននៅស្រុកភូមិកុំពិបាកគេឲ្យទៅណាឆ្ងាយៗ ។ ចឹងទៅគាត់ក៏បង្ខំចិត្តឲ្យខ្ញុំយកប្រពន្ធពីក្មេង ខ្ញុំអាយុ១៧ឆ្នាំម៉ែខ្ញុំឲ្យយកប្រពន្ធ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ ខ្ញុំប្រកែកថាមិនយកគាត់និយាយមួយម៉ាត់ថា យ៉ាងណាសូមឲ្យតែកូនតាមម៉ែទៅបើសិនជាកូនមិនតាមម៉ែទេ ទុកដូចកូនសម្លាប់ម៉ែកូនដឹងហើយតើសម័យនេះ ម៉ែបានជាជ្រុលថាកូនស្រឡាញ់គេហើយ កូនសុខចិត្តរៀបការហើយ ហើយបើសិនជាកូនប្រែទៅមិនរៀបការវិញ ម៉ែត្រូវស្លាប់ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ ខ្ញុំស្រណោះម៉ែខ្ញុំ ខ្ញុំមិនឲ្យគាត់ស្លាប់ទេ សុខចិត្តធ្មិចភ្នែកទៅរៀបការដោយមិនបានស្រឡាញ់គ្នា ។

ប៊ុនថនៈ អ្នកនៅក្នុងភូមិជាមួយពូ?

សារ៉េតៈ បាទ!ផ្ទះជិតគ្នាបាំងផ្ទះប្អូន ។

ប៊ុនថនៈ ចឹងមានធ្លាប់ស្គាល់គ្នាពីមុនមកទេ?

សារ៉េតៈ បាទ!ធ្លាប់រត់លេងជាមួយគ្នា ក្មេងជំនាន់គ្នានិងហើយវាប្អូនខ្ញុំមួយឆ្នាំ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ ខ្ញុំ១៧វា១៦ ។

ប៊ុនថនៈ ស្គាល់គ្នាពូមុនមកដែរ?

សារ៉េតៈ បាទ!ធ្លាប់លេងជាមួយគ្នា ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ ក្មេងជំនាន់គ្នានិងហើយវាប្អូនខ្ញុំមួយឆ្នាំខ្ញុំ១៧វា១៦ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ ហើយយកគ្នាទៅមានដឹងស្រឡាញ់គ្នាអី ទៅដេកនៅឯព្រៃដឹកដីស្ទូងតែស្រូវមានកំលាំងអីណាបន្តិចផង ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ យើងហត់រកតែងាប់ ហើយមកឲ្យបានគ្នាមានទៅស្រឡាញ់អីម៉ាតិច គ្រាន់តែខ្លាចថាម៉ែឪស្លាប់ដែលគាត់និយាយមូលហេតុប្រាប់ហើយក៏តាមគាត់ទៅ ។

ប៊ុនថន៖ បាទ! ហើយហ្នឹងអង្គការជាអ្នករៀបឲ្យ?

សារ៉េត៖ បាទ! ពួកខ្មែរក្រហមហ្នឹងឯងជាអ្នកចាត់ចែង គេសួរយើងថាចង់បានប្រពន្ធទេ ខ្ញុំឆ្លើយថាមិនចង់បាន តែម៉ែខ្ញុំគាត់ទៅនិយាយកូនគេរួចហើយ ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ ខាងស្រីគេអ្នកមកនិយាយមុន គេថាបងអើយយកកូនខ្ញុំឲ្យវាទៅ ឲ្យរៀបការជាប្តីប្រពន្ធទៅ កុំឲ្យគេយកទៅប្រើទៅនៅឆ្ងាយ កុំឲ្យគេចាប់ដាក់គុកដូចកូននីអីចឹងពិបាកណាស់ សព្វថ្ងៃខ្ញុំដេកភ័យដែលតើ ។ គេចាប់កូននីហើយ ព្រោះវានៅជាមួយកូននីដែរ ដល់ហើយរៀបការឲ្យវាទៅដល់ពេលហ្នឹងមេកម្មាភិបាលខ្មែរក្រហមហ្នឹងមូលដ្ឋានចាស់គេប្រមូលយើងមកគេរៀបតុកៅអីខាងនេះមួយខ្សែ ខាងនេះមួយខ្សែទុកប្រឡោះដើរកណ្តាល ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ គ្រាន់តែចាប់ដៃគ្នាតែមួយប៉ប់រលាស់ដូចយើងបុងសួរគ្នាតែប៉ុណ្ណឹង ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ អាហ្នឹងគេចាត់ទុកថាជាប្តីប្រពន្ធទៅហើយ ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ តែប៉ុណ្ណឹងឯងហើយបាយទឹកអីអត់មានទេ អត់មានសែនអត់មានព្រេនអីទេ គេគ្រាន់តែដាក់មេក្រូប្រកាសមួយម៉ាត់ពីរម៉ាត់ចប់ ។ ហើយ៥០គ្នានោះក្នុងរៀបការមួយដង៥០ទៅ១០០ពេលគេធ្វើពិធីរៀបការម្តងៗ៣០គូរទៅ៥០គូរ១០០គូហើយអត់មានពេលថ្ងៃទេ ។ នៅពេលថ្ងៃធ្វើការចាំម៉ោង៤ល្ងាចឡើងនាំគ្នាទៅការប្តីប្រពន្ធ ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ ទិកាសគេមានតែប៉ុណ្ណឹង បើថាយ៉ាងណាត្រឹមម៉ោង៣ជួបជុំគ្នាម៉ោង៤បែកគ្នាវិញទៅផ្ទះព្រឹកឡើងធ្វើការ គិតពីរឿងធ្វើការ ។

ប៊ុនថន៖ ចឹងពេលនេះហើយហ្នឹងគេមានបញ្ជូនពួទៅធ្វើការទៀតទេ ឬក៏នៅក្នុងភូមិដដែល?

សារ៉េត៖ នៅពេលរៀនការហើយហ្នឹងមានសមរភូមិមួយ អាហ្នឹងគេយកទៅតែអ្នករៀបការថ្មី អ្នកដែលរៀបការបានមួយឆ្នាំហើយអ្នកដែលរៀបការថ្មីនិងគេយកទៅដាក់ជាមួយគ្នា ។ ធ្វើជាកំលាំងកណ្តាលជាវ័យកណ្តាលឲ្យនៅធ្វើការហ្នឹងគេថាកំលាំងមាំហើយ ។ ក្រុមនិងជាក្រុមកំលាំងមាំឲ្យជីកប្រឡាយជាខ្សែៗប្រឡាយចេញពីប្រឡាយកាហាតដែលខ្ញុំនិយាយហ្នឹងដែលថាមានស្ពានបិទបើកទឹកហ្នឹងណាស់ ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ គេធ្វើចាប់ពីស៊ីនកាហតមកបុកមកខាងភ្នំប៉ាដេហើយ នៅពេលដែលខ្ញុំរៀបការរួច ដែលខ្ញុំកំពង់តែធ្វើប្រឡាយនិងឯងធ្វើស៊ីងនិងឯង ប្រឡាយធ្វើមុនពេលជំណាក់កាលទី២ គេធ្វើស៊ីង ធ្វើស៊ីងហើយ គេកែប្រឡាយសាថ្មីទៀត ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ ដល់ពេលហ្នឹងគេកាយប្រឡាយសាថ្មីជំណាក់កាលនោះឯងគេជ្រនំចល័តបានច្រើននាក់ បានរាប់ម៉ឺននាក់ហើយ គេទៅប្រែខោអាវតំរោងប្រុងផ្ទុះអាវុធ ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ ដល់ហ្នឹងទៅវាបែកបាក់គ្នាត្រង់នោះហើយ ធ្វើអីអត់កើតខ្ញុំក៏រំសាយមកផ្ទះមកយកប្រពន្ធត្រឡប់មកវិញទៅជីកអាកន្លែងនោះហើយកន្លែងប្រឡាយទៅភ្នំប៉ាដេហ្នឹង ទៅជីកតពីប្រឡាយហ្នឹងទម្លាក់ឆ្លូតស្របស៊ីងសន្តែមក ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ ឆ្លូតៗមកប្រឡាយហ្នឹងចំងាយប្រហែលជា១គីឡូគេដាក់ប្រឡាយមួយៗ សម្រាប់ឲ្យទឹកហ្នឹងស្រោចរកគ្នាដល់ ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ កាលណាគេទម្លាក់ទ្វារស្ពានថ្មនិងទៅទឹកវាបុកមកប្រឡាយធំ វាចែកមកតាមប្រឡាយតូច ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ គេឲ្យយើងធ្វើស្រែប្រាំងស្រែវស្សាអី ទឹកគេមិនខ្វះទេ កន្លែងហ្នឹងការកសាងរបស់គេហ្នឹងវាទាន់សម័យដែរ វាគ្រាន់ទាស់ថាសម្លាប់មនុស្សចោលហ្នឹង ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ ហើយធ្វើស្រូវធ្វើអង្ករបានគេដឹកយកចេញ គេមិនឲ្យយើងហូបបានគ្រប់គ្រាន់ ។

ប៊ុនថន៖ ចឹងកាលបញ្ជូនទៅហ្នឹងទៅជាមួយគ្រួសារពូ?

សារ៉េត៖ បាទ!គេឲ្យទៅជុំគ្នា ទៅជុំគ្នាហ្នឹងទៅគេតាមដានទៀត បើយើងបានគ្នាដោយមិនស្រឡាញ់គ្នាទៅដេកនិងខ្ទមមួយអាមួយដេកអង្រឹងអាមួយដេកកន្ទេលចាប់យកទៅប្រមានដូវច្បាប់គេមួយកំណាត់យប់អីចឹងទៅ ខ្វះណារហូតយកទៅវ៉ៃចោលក៏មានវាមិនចុះសម្រុងគ្នា ព្រោះមនុស្សមិនចុះសម្រុងគ្នាឲ្យទៅរៀបការជាមួយដោយបង្ខំចិត្តណាស់ ។

ប៊ុនថន៖ បាទ ។

សារ៉េតៈ ម៉ែឪបន្ទំចិត្ត ។

ប៊ុនថនៈ ចឹងមានអ្នកយកទៅវៃចោលច្រើនដែលពូ?

សារ៉េតៈ មានតើ នៅពេលដែលរៀបការទៅមិនចុះសម្រុងគ្នា គេអ្នកតាមដាន យើងទៅចឹងយើងមិនមានផ្ទះល្អទេ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ យើងមានតែគ្រែប៉ុននេះក៏ច្រូតស្បូវបាំងទៅឬគៀបបាំងទៅផ្សំៗគ្នាទៅធ្វើម៉េចកុំឲ្យតែភ្លៀងមកវាបាចវាជះ ម្ងោះហើយអាអ្នកតាមដានយើងហ្នឹងយប់ឡើងវាទៅអង្គុយចាំស្តាប់ផ្ទះនេះនិយាយគ្នាល្អឬមិនល្អមានឈ្លួសគ្នាមានមិនចុះសម្រុងរួមដំណេកអីចឹងទៅវាយកការណ៍ច្បាស់ អាកន្លែងហ្នឹង ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ ម្ងោះហើយកន្លែងណាវាគួរកសាងវាកសាងកន្លែងណាវាមិនគួរកសាងវាទាញយកទៅវៃចោលក៏បាន ។

ប៊ុនថនៈ ចឹងពូនៅហ្នឹងអត់អីទេ?

សារ៉េតៈ អត់អីទេ ខ្ញុំនៅក្មេងមែនតែខ្ញុំគិតឃើញម៉ែឪខ្ញុំពន្យល់ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ សង្គមហ្នឹងវាមិនអាចរស់នៅបានយូរទេ ប្រពន្ធទោះបីស្រឡាញ់មិនស្រឡាញ់យកតាមម៉ែសិនទៅ ម៉ែបានជាខុសមិនបានសួរកូន កាលពីដើមមិញគាត់ធ្លាប់និយាយដែលថា គាត់ទុកកូនហ្នឹងឲ្យខ្ញុំ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ ដល់ហ្នឹងពុថាទុកខ្ញុំមិនស្រឡាញ់រហូត ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ តែកាលហ្នឹងខ្ញុំគ្រាន់តែយល់ដល់ចិត្តគាត់ គាត់និយាយថាឯងមិនព្រមធ្វើតាមគាត់ គេយកគាត់ទៅសម្លាប់ចោល ខ្ញុំទោះបីជាមិនស្រឡាញ់យ៉ាងណាចេះតែដេកៗទៅ ខ្ញុំមិនឈ្លួសមិនប្រកែកដល់ពេលគេរំសាយ ខ្ញុំនៅកន្លែងហ្នឹងចេះតែនៅៗទៅ ស្រាប់តែពុស្សូវ្យគេចាក់ចាប់ប៉ុស្តិ៍ភ្នំពេញបាន ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ គេចាក់ភ្លេងខ្មែរយើងពីដើម ពេលហ្នឹងខ្មែរក្រហមវាផ្អើលអស់ ។

ប៊ុនថន: បាទ ។

សារ៉េត: វាអត់មានគិតពីរឿងចល័តពីរឿងអីទេ វាមិនមានគិតពីរឿងការកសាងអីទេ វាចលាចល រៀងៗខ្លួនហើយទ័ពវារត់របួសអីក៏មិនមានពេទ្យ មិនមានថ្នាំអីទេវាគិតតែពីរត់ភ័យផ្អើលដូច យើងគោហ្វូងចឹង ពពូនពពាក់បែកបាក់ការសាមគ្គីរបស់វាអស់កាលនោះ ខ្ញុំក៏មកផ្ទះវិញមក ដល់ផ្ទះនាំម៉ែឪចូលមកនៅកន្លែងយួនឈប់នៅជាមួយខ្មែរក្រហម ។

ប៊ុនថន: បាទ ។

សារ៉េត: យួនចូលដល់បាត់ដំបងពីបាត់ដំបងទៅយួនវាឡើងប្រហែលជាបីគីឡូ ដូច្នេះខ្ញុំនាំឪពុកម្តាយខ្ញុំ ពីស្រុកខ្ញុំមកវាឆ្លងកាត់ដីចំនួន៧គីឡូ មកនៅខាងតំបន់ដែលយួនកាន់កាប់បានរួចខ្លួនរហូតដល់ សព្វថ្ងៃហ្នឹង កាលហ្នឹងប្រពន្ធខ្ញុំ ខ្ញុំឲ្យទៅម៉ែគេវិញទៅ ។

ប៊ុនថន: បាទ ។

សារ៉េត: ខ្ញុំក៏នៅជុំជាមួយម៉ែខ្ញុំវិញ ។

ប៊ុនថន: នៅភូមិវិញពូ?

សារ៉េត: នៅស្រុកភូមិធម្មតា ។

ប៊ុនថន: ចឹងក្រោយមកទៀតពូមានទៅរស់នៅណាទៀតដែរ?

សារ៉េត: ក្រោយមកនៅសម័យហ្នឹងមានយួនម្នាក់ដែលគាត់រស់នៅក្នុងតំបន់ភូមិខ្ញុំហ្នឹងណាស់ ។

ប៊ុនថន: បាទ ។

សារ៉េត: គាត់នៅធ្វើចៅកែក្រុច ឪពុកគាត់និងចៅកែក្រូចហើយគាត់មានកូនប្រុសគាត់មួយនៅពេល ដែលបងថ្លៃខ្ញុំហ្នឹងទៅធ្វើកម្មករក្រូចហ្នឹង រកស៊ីបូមទឹកដាក់ក្រូចឲ្យគាត់ខ្ញុំដើរតាម ដើរតាម បងថ្លៃខ្ញុំគាត់ នៅពេលហ្នឹងកូនយួនហ្នឹងកូនកំលោះគាត់និងគាត់ស្គាល់ខ្ញុំ ។

ប៊ុនថន: បាទ ។

សារ៉េត: គាត់ស្គាល់ខ្ញុំដល់ពេលសម័យយួនចូលស្រុកឆ្នាំ៧៩ហ្នឹង គាត់យកខ្ញុំឲ្យទៅធ្វើជាក្រុមជំនាញ ការ ដើរតាមចៅហ្វាយខេត្ត ។

ប៊ុនថន: កាលហ្នឹងចៅហ្វាយខេត្តអីវិញ?

សារ៉េត: ចៅហ្វាយខេត្តឈ្មោះ គង់ ស ។

ប៊ុនថន: បាទ ។

សារ៉េត: នៅបាត់ដំបង នៅពេលហ្នឹងគេចោទគាត់ថា គាត់ចូលដៃជើងខាងប៉ារ៉ា ។

ប៊ុនថន: បាទ ។

សារ៉េត៖	គេក៏ចាប់គាត់បាត់ទៅដាក់គុកទៅ ដល់ខ្ញុំជាអ្នកការពារនេះនៅពេលដែលគេចាប់នាយថៅហ្វាយ អាពួកខ្ញុំហ្នឹងវាគិតអីមិនឃើញទេ ថាគេចាប់មេហើយយើងមិនដែលយូរទេ ។

ប៊ុនថន៖	បាទ ។

សារ៉េត៖	នាំគ្នាគេចខ្លួនមិនដឹងជាគេចទៅណា ដល់នេះនាំគ្នាដើរតាមផ្លូវមក ដល់ដើរៗហ្នឹងក៏ជួបខ្មែរក្រហម អះ!ជួបប៉ុលពតនៅជំរំថ្មីគេក៏ដកកាំភ្លើងខ្ញុំអស់រលីង ខ្ញុំក៏អស់សិទ្ធត្រឹមនោះឯងធ្វើជាអ្នកស្រុកដើរប៉ែលែប៉ែឡោទៅ រកកន្លែងពឹងមិនឃើញមិនដឹងគិតថាទៅណា ។

ប៊ុនថន៖	បាទ ។

សារ៉េត៖	ហើយក៏មានពួកម៉ាកមួយ អាពួកម៉ាកនោះវាទៅអាមេរិចចោលខ្ញុំហើយ វាថាតោះយើងបើទៅផ្ទះវិញជាប់គុក ទៅយួនចាប់ដាក់គុកហើយ ។

ប៊ុនថន៖	បាទ ។

សារ៉េត៖	មិនបាច់ទៅទេ ដល់វានិយាយចេះខ្ញុំក៏គិតឃើញតាមវា មានអីយើងរត់មកប៉ុននេះហើយអស់កាំភ្លើងពីដៃរលីងទៅវិញយួនចាប់ដាក់គុកហើយ ដល់ពេលនេះវានាំមកធ្វើប៉ុលពត នាំមកធ្វើប៉ុលពតធ្វើបានពីឆ្នាំ៨០ដល់៨៤បានបួនឆ្នាំ ។

ប៊ុនថន៖	បាទ ។

សារ៉េត៖	បានបួនឆ្នាំខ្ញុំមើលទៅក្រឡាពួកហ្នឹង ដើរនយោបាយមិនស្អាតមានអាប្រឆាំងគ្នាឯងក៏មានអាអ្នកធំសម្លាប់គ្នាឯងក៏មាន ដល់ខ្ញុំគិតៗមើលទៅអ្នកដែលធ្វើការតស៊ូជាមួយបើដូចជាឯកឧត្តមសឺន សាននោះគាត់ជាអ្នកស្នេហាពិតប្រាកដរបស់គាត់ៗ តែអាអ្នកដឹកនាំក្រោមៗគាត់ដូចជាមានតែគំនិតក្បត់គ្នា បន្តិចអាអ្នកធំនោះសម្លាប់អ្នកធំនេះ រឿងរ៉ាវតែគ្នាវាអាប៉ុលពតហ្នឹង ។

ប៊ុនថន៖	បាទ ។

សារ៉េត៖	ដល់ពេលហ្នឹងខ្ញុំមើលទៅឃើញថានយោបាយមិនល្អទេ ខ្ញុំឈប់ ខ្ញុំសុំឈប់គេចង់យកខ្ញុំទៅបាញ់ចោល ខ្ញុំភ័យពេលនោះ ដល់ម្នាក់នោះសុំឈប់គេយកទៅបាញ់ចោលមែន ថាខ្ញុំមកខ្ញុំមិនបានមកសុំអង្គុយមកនៅជាមួយអ្នកឯងទេ ។ ខ្ញុំមកដោយខ្លួនខ្ញុំ ឥឡូវបើខ្ញុំដើរហួសម៉ោងហួសពេលខុសច្បាប់ទម្លាប់មួយថ្ងៃពីរថ្ងៃរករឿង ។ ខ្ញុំក៏មិននៅជាមួយអ្នកឯងដែលខ្ញុំទៅផ្ទះវិញ ខ្ញុំទៅនៅរកស៊ីឡើងត្នោតវិញធ្វើស្ករនោះវិញចិញ្ចឹមប្រពន្ធប្រយោជន៍ជាង ដល់គាត់និយាយចុះយកគាត់ទៅបាញ់ចោល ។

ប៊ុនថន៖	បាទ ។

សារ៉េតៈ អាមេប៉ារាហ្នឹង ខ្ញុំឃើញចុះដល់នេះខ្ញុំដាក់ឌីម៉ង់ខ្ញុំសរសេរកាលនោះមានបងប្អូនខ្ញុំធ្វើការនៅកន្លែងនាយកកដ្ឋានខាងកសិកម្ម ខ្ញុំទៅសុំក្រដាសរាមគាត់ពីរសន្លឹកមកខ្ញុំសរសេរជាឌីម៉ង់ដាក់ពាក្យសុំឈប់ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ ដល់ពេលហ្នឹងគាត់យកទៅមើល ដល់ហើយគាត់ថាអី អានេះបានគេហៅមនុស្សកុំថាសួរថាឈប់ថាមិនឈប់ទេ ដល់ពេលហៅប្រើហៅមិនបានអាហ្នឹងដែលយកទៅបាញ់ចោល ។

ប៊ុនថនៈ កាលហ្នឹងប្រធានពីណាវិញពូ?

សារ៉េតៈ ប្រធានហ្នឹងមិនរស់ទេស្លាប់ហើយ ឈ្មោះគាត់ ជា ថៃនៅភ្នំស្រុកនេះ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ បើនិយាយទៅគាត់មិនគួរធ្វើដល់ប៉ុណ្ណោះទេ គាត់ហ្នឹងមនុស្សយ៉ាងល្អគាត់ចាងហ្វាងសាលាបឋមសិក្សានៅភ្នំស្រុក ។

ប៊ុនថនៈ ជា ថៃហ្នឹង?

សារ៉េតៈ បាទ! គាត់មិនមែនកាលីបទាបប៉ុន្មានទេ គាត់ជាចាងហ្វាងសាលាដែរ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ ហើយដល់ពេលហ្នឹងគាត់សម្លាប់មនុស្សដោយមិនរើសមុខ គ្រាន់តែអ្នកនៅធ្វើប៉ារាហ្នឹងគ្នាត្រឡប់មកវិញជាប់តែអង្រឹងមួយហ្នឹងជាប់ចង្កេះរត់មកផ្ទះ បើហ៊ានតែតាមទាន់ត្រង់ណាចាប់បាញ់ចោលដូចសត្វ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ គ្មានពិចារណាអីទាំងអស់ ខ្ញុំគិតឃើញថាចឹងមិនកើតទេចឹងសុំលាលែងឈប់ហើយតែខ្ញុំដាក់ដីម៉ង់សុំច្បាប់ឈប់សាកមើល ដល់ធ្វើទៅគាត់យកទៅមើលគាត់ផ្ទក់ក្បាលអាហ្នឹងបានគេហៅមនុស្ស ។ បើឈប់ឲ្យដឹងថាឈប់ ធ្វើដីម៉ង់មកអញមិនខ្វាចនិងស៊ីញ៉េឲ្យទេ ទៅដល់គាត់ស៊ីញ៉េខ្មោកៗឲ្យមកខ្ញុំ អាមួយគាត់យកទុករបស់គាត់ មានអាមេរង់នោះមករករឿងខ្ញុំមិនចង់ឲ្យខ្ញុំឈប់ទេ ដល់ហើយខ្ញុំថានេះដីម៉ង់ខ្ញុំមានហើយ ខ្ញុំមុននិងឈប់ខ្ញុំដាក់ដីម៉ង់សុំឈប់ឥឡូវស៊ីញ៉េឲ្យខ្ញុំហើយមានពិបាកអីទៀត ហៅខ្ញុំទៅវិញខ្ញុំមិនទៅ ដល់នេះខ្ញុំទៅធ្វើការនៅនាយកកដ្ឋានកសិកម្មខ្ញុំឈប់បំរើខាងប៉ារា ។

ប៊ុនថនៈ ខាងកសិកម្មហ្នឹងខាងណាវិញ?

សារ៉េតៈ ខាងរណសិរ្ស ។

ប៊ុនថនៈ ខាងរណសិរ្សខាងណា?

សារ៉េតៈ ខាងសឹន សាន ។

ប៊ុនថនៈ ចឹងលោកពូពីមុននៅខាងកងទ័ពហើយមកខាងកសិកម្ម?

សារ៉េតៈ បាទ!ខ្ញុំដាក់ដីម៉ងសុំឈប់ពីកងទ័ព ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ ខ្ញុំមើលទៅឃើញសម្លាប់មិនពិចារណា ខ្ញុំគិតឃើញថាខ្មែរក្រហមសម្លាប់គ្នាឯង ដល់នេះសម្លាប់ចេះទៀតខ្ញុំមិននៅជាមួយទេ ។

ប៊ុនថនៈ បាទ!ចឹងកាលពូចូលហ្នឹងមានឡើងវ៉ៃអីទេ?

សារ៉េតៈ ខ្ញុំធ្វើរយៈពេលនោះអត់មានដែលបានចុះទៅណាទេ មេគេស្រឡាញ់ខ្ញុំដែលនោះ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ គេឲ្យខ្ញុំនៅបើមានការយួនឡើងទៅវ៉ៃទីតាំងធំនៅនោះ មានបានប៉ះពាល់បន្តិចបន្តួច ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ បើថាមិនមានឡើងវ៉ៃទេ បើថាមកតាមខ្មែរអីខ្ញុំនៅនោះបួនឆ្នាំខ្ញុំបានមកនេះតែមួយយប់ពីរយប់តែប៉ុណ្ណឹងឯង ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ បានមកក្នុងភូមិហ្នឹង តែមិនបានចូលភូមិទេ មកខាងភូមិអំពិលទៅដេកនិងអាំងបានពីរយប់ទៅផ្ទះវិញប៉ុណ្ណោះឯងមិនដែលបានទៅណាទេ ។

ប៊ុនថនៈ ហ្នឹងមកល្បាតឬមួយមក?

សារ៉េតៈ មកហ្នឹងកាលនោះគេប្រើ គេប្រើឲ្យមកទិញគោ ទិញគោអ្នកដូនដាល ដឹកស្រូវខាងរំដួល ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ គេទិញឲ្យទៅ គេផ្ដាំឲ្យមកយកដឹកកាត់ព្រៃតាមនេះយកទៅឲ្យជប់លៀងទ័ពគេលើនោះ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ តែយកទៅក៏មិនបានជប់លៀងទេ ដល់ថ្ងៃនោះយួនវាតាមស្អិតៗទៅវ៉ៃជំរំបែកថ្ងៃហ្នឹង គោនៅពេញឆ្នាំងមិនបានស៊ីផង ។

ប៊ុនថនៈ បាទ!ជំរំអីវិញកាលហ្នឹង?

សារ៉េតៈ កាលនោះគេហៅជំរំតាស្រី ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ គេហៅដំរីតាស្រី ភូមិតាស្រី ដំរីនោះវានៅខាងកើតដំរីសាយធូ ។

ប៊ុនថនៈ បាទ! នៅក្នុងទឹកដីថៃ?

សារ៉េតៈ នៅដីខ្មែរនៅព្រំប្រទល់ ។

ប៊ុនថនៈ នៅក្នុងស្រុកអីវិញពូ?

សារ៉េតៈ នៅជាប់ស្រុកថៃភូមិស្រង៉ែ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ នៅគេហៅព្រៃមាន់អូរកំបុតសព្វថ្ងៃហ្នឹងណាស់ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ តពីបឹងត្រកួនទៅជាយដែនហ្នឹង ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ តែខ្ញុំនៅខាងកើតខាងជើងភូមិស្រង៉ែ នៅកៀនភ្នំដងរែកនោះ ។

ប៊ុនថនៈ កាលពូនៅហ្នឹងមានខ្មែរក្រហមអីទេ?

សារ៉េតៈ ខ្មែរក្រហមកាលពីខ្ញុំទៅនៅដំបូងកាលពីឆ្នាំ៨០ - ៨១ មាននៅព្រៃមាន់មាននៅតាមជួរភ្នំដងរែក ។

ប៊ុនថនៈ ចឹងជាប់កន្លែងពូដែរ?

សារ៉េតៈ បាទ! គេនៅតៗពីខ្ញុំដល់ពេលខ្ញុំទៅនៅហ្នឹង កំលាំងខាងរណសិរ្សហ្នឹងគាត់ចេះតែធ្វើនយោបាយបង្កើនទ័ពបានដល់រាប់ពាន់រាប់ម៉ឺនទៅខ្មែរក្រហមបាត់អស់ មិនដឹងជាទៅណា ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ វាចុះទៅនៅខាងព្រះវិហាឯនោះវិញ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ ហើយមកនៅខាងនេះ នៅព្រៃមាន់បន្ទិចភ្នំឆត្របន្តិចនោះហើយ ។

ប៊ុនថនៈ ហ្នឹងខ្មែរក្រហម?

សារ៉េតៈ ហ្នឹងហើយមានតែប៉ុណ្ណោះឯង ។

ប៊ុនថនៈ តែមានប៉ះគ្នាអីទេ?

សារ៉េតៈ រឿងខ្មែរក្រហមជាមួយប៉ារ៉ាភនេះមិនដែលឈ្លួសគ្នាទេ បើថានៅចេះយើងទៅនៅបានតែពីរបីថ្ងៃវាឲ្យកូនចៅវាមកទាក់ទងជាមួយកូនចៅយើងទៅរហូតបានទាក់ទងបានដល់មេទៅទទួលស្គាល់គ្នាចាប់ដៃមិនច្បាំងគ្នា ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ បើយួនទៅវ៉ៃយើងសហការគ្នា យើងកុំវ៉ៃខ្មែរគ្នាឯងនាំតែយួនវាអរ យើងវ៉ៃខ្មែរគ្នាឯង យើងស្លាប់តែខ្មែរគ្នាឯង ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ យួនគេមិនបានស្លាប់ជាមួយយើងទេ ។

ប៊ុនថន៖ បាទ!ចឹងពូនៅខាងកសិកម្មហ្នឹងពូនៅជំរំនិងដែរ?

សារ៉េត៖ នៅជំរំសាយធូ ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ ដែលខ្ញុំឈប់ពីទាហានទៅ កាលហ្នឹងគេចូលជំរំសាយធូហើយខ្ញុំសុំគេឈប់ ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ សុំគេឈប់ខ្ញុំនៅខាងកសិកម្មវិញ ។

ប៊ុនថន៖ ពូនៅយូរដែលទេ?

សារ៉េត៖ នៅខាងកសិកម្មខ្ញុំនៅបានពីរឆ្នាំ ឆ្នាំ៨៤-៨៥-៨៦-៨៧នៅយូរគ្រាន់ ខ្ញុំនៅតាំងពីឆ្នាំ ៨៤មកដល់៨៧-៨៧-៨៩-៩០ដល់៩១បានខ្ញុំមកនេះ ។

ប៊ុនថន៖ បាទ!តែខាងកសិកម្មហ្នឹងធ្វើការងារអីវិញពូ?

សារ៉េត៖ ខ្ញុំបើកន្ធែងតាមជំរំគេដំណាំដកពិសោធន៍និងចិញ្ចឹមសត្វដកពិសោធន៍ ធ្វើស្រែដកពិសោធន៍ ។

ប៊ុនថន៖ តែគេអត់មានបង្កើតដូចជាស្ថាប័នឥឡូវមានក្រសួងមានអីទេ?

សារ៉េត៖ កសិកម្មហ្នឹងមានក្រសួងកសិកម្មនិងវាមាននៅតាមជំរំ ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ ហើយវាមាននាយកកដ្ឋានគេ ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ គេធ្វើដូចយើងនៅស្រុកខ្មែររាល់ថ្ងៃហ្នឹង ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ មាននាយកកដ្ឋានចឹងទៅសម្រាប់ចែកចាយទៅតាមជំរំចឹងទៅ ។

ប៊ុនថន៖ បាទ!ចឹងគេមានផ្នែកៗគេដែរ?

សារ៉េត៖ បាទ!មានផ្នែកៗទៅតាមជំរំ មានផ្នែកខាងពេទ្យសត្វ មានខាងដំណាំដាំដុះចឹងទៅ មានខាងដកពិសោធន៍ដំណាំស្រូវយើងហ្នឹង ។

ប៊ុនថន: បាទ!ចឹងនិយាយថាគេមានបែងចែកផ្នែកៗ ដែលលោកតូ?

សារ៉េត: បាទ ។

ប៊ុនថន: ចឹងនៅហ្នឹងបានយូរហើយតូដែលនិយាយថាពីមុនមកតូបានចុះមកភូមិហ្នឹងនិយាយថាឃើញមានប្រជាជនរស់នៅច្រើនទេតូ?

សារ៉េត: នៅភូមិនេះ ។

ប៊ុនថន: បាទ ។

សារ៉េត: នៅសម័យហ្នឹងកាលដែលខ្ញុំចុះមកហ្នឹង ភូមិយើងខាងនេះមនុស្សនៅជួបជុំគ្នាទេ មិនមានបែកបាក់អីទេ ដូចថាភូមិផ្លាំមានមួយចំនួនទៅនៅខាងទំបន់រណសិរ្សនោះ ។

ប៊ុនថន: បាទ!ចឹងចេញពីភូមិហ្នឹងទៅនៅជាមួយ?

សារ៉េត: បាទ!ដូចខាងបន្ទាយឆ្មាអី ស្វាត់ទាំងស្រុកមានពាក់កណ្ដាលឡើងទៅនៅតំបន់រណសិរ្សនោះ ហើយមួយចំនួនទៀតគេមកនៅតាមថ្មពួក ខ្លះទៅនៅស្រុកគេខាងកើតនោះទៅខាងបេងខាងគោគមននោះ ។

ប៊ុនថន: បាទ ។

សារ៉េត: ចំពោះភូមិបន្ទាយឆ្មាគឺអស់រលីង មានបន្ទាយឆ្មាគោកសំរោង ។

ប៊ុនថន: បាទ ។

សារ៉េត: ភូមិធ្លក ភូមិត្បែងអត់មានមនុស្សម្នាក់មួយទេ ។

ប៊ុនថន: បាទ ។

សារ៉េត: ជម្លៀសអស់ ។

ប៊ុនថន: ចឹងនៅនេះពីណាគ្រប់គ្រង កាលតូចូលមកហ្នឹង?

សារ៉េត: កន្លែងនេះ ។

ប៊ុនថន: បាទ ។

សារ៉េត: កាលនោះមិញ គាត់ងាប់ហើយឈ្មោះគាត់ តា សុខគាត់ធ្វើប្រធានភូមិ ។

ប៊ុនថន: តែគាត់ខាងណាវិញតូ ខាងខ្មែរក្រហមខាងប៉ុលពតខាងវៀតណាម?

សារ៉េត: ខាងវៀតណាមមេភូមិ ។

ប៊ុនថន: បាទ ។

សារ៉េត: កាលហ្នឹងខាងគណបក្សប្រជាជនរឹងជាប់មួយជួរនេះ ដើរមិនបានផង ។

ប៊ុនថន: បាទ!ចឹងកាលហ្នឹងតូចូលមកមិនមែនចូលក្នុងភូមិតែម្ដង?

សារ៉េត៖ អត់ទេ អត់ហ៊ានទេ ខ្ញុំមកហ្នឹងខ្ញុំចូលតែតាមព្រៃលាក់ៗខ្លួន ។

ប៊ុនថន៖ ចឹងពូមកដល់នេះដល់ឆ្នាំ៩៣បានពូមកដល់នេះ?

សារ៉េត៖ បាទ!ខ្ញុំមកនៅឆ្នាំ៩៣ដែលគេបោះឆ្នោត ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ កាលឆ្នាំ៩២ខ្ញុំមក ផ្ញើមាតុភូមិនៅឆ្នាំ៩២ ។

ប៊ុនថន៖ ចឹងមកពីជំរំ?

សារ៉េត៖ មកពីជំរំសាយធូ ។

ប៊ុនថន៖ ចឹងកាលនៅឆ្នាំ៩២ហ្នឹង ក្នុងភូមិយ៉ាងម៉េចដែលសន្តិសុខអីខាងខ្មែរក្រហមនៅតែមានឬខាងប៉ុរាមានកំលាំងនៅហ្នឹងដែរ?

សារ៉េត៖ បាទ!សម័យដែលខ្ញុំមកហ្នឹងជំនាន់នោះនៅពិបាកមើលនៅឡើយ ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ ខ្មែរក្រហមក៏នៅក្នុងភូមិនេះប៉ុរាក៏នៅក្នុងភូមិនេះ កងពលក៏នៅនេះវិលវិគ្នា ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ មួយចេញមួយចូល ។

ប៊ុនថន៖ ចឹងពូនៅប៉ុរាដដែលកាលហ្នឹង?

សារ៉េត៖ អត់ទេ ខ្ញុំឈប់ហើយ ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ ខ្ញុំចេញពីប៉ុរានៅខាងកសិកម្មប្រទ្ធានប្រហែលជា១០ឆ្នាំនោះ ខ្ញុំរាប់មើល ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ ពី៨៤រហូតដល់ឆ្នាំ៩២ ខ្ញុំត្រូវចុះមាតុភូមិនិវត្តន៍មក ។

ប៊ុនថន៖ បាទ!ចឹងពូរស់នៅយ៉ាងម៉េចដែលកាលចូលមកនៅជំបូងហ្នឹងដូចថាកំលាំងបីចម្រុះគ្នា?

សារ៉េត៖ វា កាលនោះដល់ពេលខ្ញុំមកភូមិយើងនេះវាអត់មានទ័ពណាពិតប្រាកដឈរជើងទេណាស់ ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ វាគ្រាន់តែថាខ្មែរក្រហមគេមកចឹងទៅបីបួនថ្ងៃគេទៅវិញ បន្តិចប៉ុរាឡើងមកចឹងទៅមកនៅមួយថ្ងៃឬកន្លះថ្ងៃគេទៅវិញ ។

ប៊ុនថន៖ បាទ ។

សារ៉េត៖ ព្រោះនៅក្នុងនេះកងពលគាត់នៅនេះ ។

ប៊ុនថន: បាទ ។

សារ៉េត: ម្លោះហើយអ្នកដែលនៅនេះមិនសូវហ៊ានទេ ។

ប៊ុនថន: ចឹងមានប្រយុទ្ធគ្នាអីទេ ក្នុងភូមិនេះមានប៉ះគ្នាទេ?

សារ៉េត: ពីសម័យពីមុនកាលខ្ញុំនៅជំរំសាយធូនៅឡើយ ភូមិនេះតែងមានប្រទាញប្រទង់គ្នារឿងខ្មែរក្រហមជាមួយកងពលបាញ់ឆេះផ្ទះអីចឹងទៅ ។

ប៊ុនថន: បាទ ។

សារ៉េត: ហើយភូមិនេះកងពលធ្វើបាបណាស់ គេថាភូមិនេះសម្បូរប្រពន្ធខ្មែរក្រហម ។

ប៊ុនថន: បាទ ។

សារ៉េត: កាលណាគេចូលមកចឹងគេរករឿងអ្នកស្រុក គេដើរបាញ់គោបាញ់ជ្រូកចោលតាមផ្ទះណាស់ ហើយអ្នកស្រុកគ្នារត់ទៅនៅតាមព្រៃតាមអីខ្លះទៅ ខ្លះក៏នៅហ្នឹងនៅ ។

ប៊ុនថន: ចឹងមានចាប់អីអ្នកស្រុកដែរ?

សារ៉េត: មិនមានចាប់ទេ ។

ប៊ុនថន: ចឹងមានតែគំរាម?

សារ៉េត: បាទ! គ្រាន់តែគំរាមៗមកសម្លុតអ្នកឯងមានកូនធ្វើខ្មែរក្រហមមានអីចឹងទៅណាស់ ។

ប៊ុនថន: បាទ! ចឹងខាងខ្មែរក្រហមខាងប៉ៃលិនអីមានគំរាមកំហែងអ្នកភូមិទេ?

សារ៉េត: ពួកហ្នឹងគេអត់មានដែលគំរាមទេ បើគេមកស្នាក់នៅចឹងគេសុំបាយកញ្ចប់មួយពេលអីប៉ុណ្ណឹងហើយទៅវិញ ជួនកាលគេមកឈរជើងមួយថ្ងៃពីរថ្ងៃអីចឹង ។

ប៊ុនថន: បាទ! ចឹងមានប៉ះគ្នាអីប្រជាជនគាត់រស់នៅយ៉ាងម៉េចដែរ រកស៊ីឬមួយធ្វើស្រែចឹងពូ?

សារ៉េត: មានប៉ះគ្នាហ្នឹង នៅពេលចេញទៅធ្វើស្រែអីចឹងទៅមានគេប្រាប់ថាកងពលឡើងដល់ត្រង់នេះដល់ត្រង់នោះ ខ្មែរក្រហមមាននៅនេះគេចទៅ ។

ប៊ុនថន: បាទ ។

សារ៉េត: គេចចូលទៅព្រៃនេះហើយ ទៅព្រៃមាន់ខាងកើតនោះ ។

ប៊ុនថន: បាទ ។

សារ៉េត: ជួនកាលទៅវាបាញ់ជ្រលបន្តិចបន្តួចទៅឆេះស្រូវឆេះផ្ទះ ងាប់មនុស្សអីខ្លះ ។

ប៊ុនថន: ចឹងនៅពេលខាងវៀតណាមដកទៅខាងនោះចូលមកវិញ?

សារ៉េត: បាទ! ចេញចូលៗ ថាមានថ្ងៃណានេះបាញ់គ្នាបីដង ។

ប៊ុនថន: ចឹងមានគ្រោះថ្នាក់ដល់អ្នកភូមិទេ?

សារ៉េតៈ មានផាប់ ត្រូវគាប់ហើយយកទៅដេកពេទ្យទៅជំរំចឹងទៅបញ្ជូនទៅខាវដាងទៅមើលមិនជាបញ្ជូនមកវិញផាប់នៅផ្ទះ ។

ប៊ុនថនៈ បាទ!ចឹងរហូតដល់ឆ្នាំណាបានមានការគ្រប់គ្រងច្បាស់លាស់មានសន្តិសុខអី?

សារ៉េតៈ មានសន្តិសុខគ្រប់គ្រាន់ទាល់ដល់ដំណាក់កាលដែលយើងបោះឆ្នោតអណ្តិតទី២ ។

ប៊ុនថនៈ ៩៨?

សារ៉េតៈ បាទ!កាលមានហើយឈប់មានអីអស់ហើយ ។

ប៊ុនថនៈ ចឹងមានមីនអីដែលនៅនេះ?

សារ៉េតៈ មីនមាន កន្លែងនេះហើយដែលខ្ញុំនិយាយថាព្រៃមីននេះហើយ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ ស៊ីម៉ាក់គេមកដោះឡើងបីខែ ។

ប៊ុនថនៈ មានច្រើនទេពូ?

សារ៉េតៈ ដោះបានច្រើនតែតើកន្លែងហ្នឹង កន្លែងហ្នឹងខ្មែរក្រហមវាផ្ទុះឃ្លាំងគ្រាប់ឃ្លាំងរំសេវវាហើយវាដាក់មីនការពារ រហូតដល់អ្នកធ្វើស្រែនោះធ្វើទៅភ្ជួរចឹងទៅអណ្តែតមីនឡើង ដូចខ្ញុំគេដោះមីនរួចហើយទៅចាប់ដី គេវាស់ដីឡូធ្វើភូមិខ្ញុំចាប់ដីមួយកន្លែងជីកៗទៅអណ្តែតមកកូនមីនតូចៗប៉ុននេះ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ តែវារលួយអស់ហើយ ឈប់ផ្ទុះអីអស់ហើយ ។

ប៊ុនថនៈ អត់មានគ្រោះថ្នាក់អីដែលពូ?

សារ៉េតៈ អត់ទេ មិនដែលមានគ្រោះថ្នាក់ដល់ប្រជាជន វាគ្រោះថ្នាក់កាលមិនទាន់ដោះមីនកាលហ្នឹងពួកហ្នឹងវាទៅលួចគ្រាប់លួចអី ខ្មែរក្រហមយកមកលក់អីកាលហ្នឹងមានផ្ទុះមីនត្រូវរបួសត្រូវអី ។

ប៊ុនថនៈ ចឹងកន្លែងឃ្លាំងហ្នឹងនៅមានគ្រាប់ផ្ទុះ?

សារ៉េតៈ បាទ!ត្រឹមឃួនដកថយចេញផុតទៅ ខ្មែរក្រហមក៏វាគាស់គ្រាប់ប្រមូលយកទៅណាអស់បាត់នៅសល់តែមីនកប់ក្នុងដីបន្តិចបន្តួចហ្នឹង ស៊ីម៉ាក់គេចូលដោះបំផ្លាញកំទេចចោលអស់ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ សព្វថ្ងៃគេបង្កើតភូមិនៅហ្នឹង ។

ប៊ុនថនៈ បាទ!ចឹងពូមកមានគ្រួសារពេលណាទៀត?

សារ៉េតៈ ខ្ញុំហ្នឹង ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ គ្រួសារខ្ញុំបើនិយាយទៅវាចូលបីដំណាក់កាល ដែលខ្ញុំបានជំនាន់ប៉ុល ពតហ្នឹងម្តង ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ ក្រោយមកខ្ញុំមកបាននៅភូមិនេះហើយ ខ្ញុំនៅកសិកម្មនោះ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ ខ្ញុំបានអ្នកភូមិនេះមួយ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ បានកូនបីនាក់ឈឺស្លាប់កាលពីឆ្នាំ៩០ប៉ុន្មាន...ចូលឆ្នាំ២០០២ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ ដល់ហ្នឹងខ្ញុំមានតែកូនប្រុសពីរនាក់ កូនប្រុសក៏គេដើរចោលខ្ញុំមិនដែលនៅផ្ទះសំបែងផងខ្ញុំចាស់ហើយរោគការកបពឹងមិនឃើញ ខ្ញុំប្រុសទៅនៅស្រុក ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ បានម្តាយមីងនោះគាត់រកប្រពន្ធឲ្យនៅនេះទៅ កូននោះមានពីរនាក់នោះគេទៅនៅបាងកកសព្វថ្ងៃ ។

ប៊ុនថនៈ ចឹងទៅដល់បាងកក?

សារ៉េតៈ បាទ ។

ប៊ុនថនៈ ចឹងគ្រួសារបងក្រោយបានប៉ុន្មាននាក់ដែរ?

សារ៉េតៈ បានមួយនិងឯង ។

ប៊ុនថនៈ បាទ!តូចដែលអាយុប៉ុន្មាន?

សារ៉េតៈ បួនឆ្នាំហើយ ។

ប៊ុនថនៈ ចឹងនៅតំបន់នេះមានសមាហរណ៍កម្មដែរ?

សារ៉េតៈ សមាហរណ៍កម្មមានតើ ។

ប៊ុនថនៈ តំបន់ស្វាយចេកពួកនេះឆ្នាំណា សមាហរណ៍កម្ម?

សារ៉េតៈ ឆ្នាំខ្ញុំភ្លេចបាត់ហើយ ។

ប៊ុនថនៈ ក្រោយមកស្រួលបួលហើយជីវភាពអ្នកភូមិមានការផ្លាស់ប្តូរយ៉ាងម៉េចដែរ នៅក្នុងភូមិឆ្នាំនេះ?

សារ៉េតៈ ក្រោយពីសង្គ្រាមឆ្លងកាត់ផុតមកជីវភាពអ្នកស្រុកឃើញថា មានការរីកចំរើន ។

ប៊ុនថនៈ បាទ!មានប្លែកច្រើនដែលពូ?

សារ៉េតៈ បាទ!មានរីកចំរើនច្រើនជាងពីសម័យយើងពីមុនមក ។

ប៊ុនថនៈ បាទ!ចឹងជីវភាពគាត់?

សារ៉េតៈ ជីវភាពគាត់ធូរធារជាងពីដើម ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ សម័យយើងប្រឡូកប្រឡាក់គ្នានោះ ណាមួយប្រជាពលរដ្ឋគ្នាមិនហ៊ានចេញទៅធ្វើស្រែឆ្ងាយផង ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ ហើយណាមួយជួបប្រទះការរាំងស្ទួនផង ហើយជួបប្រទះកងកំលាំងខាងទ័ពខ្មែរក្រហមវាខស្សាហ៍ហៅប្រជាពលរដ្ឋទៅដឹកជញ្ជូនគ្រាប់អីចឹងទៅ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ មានគ្រោះថ្នាក់មានអី ហើយមួយទៀតស្រូវអង្ករគ្នាធ្វើបានជួនកាលទៅមានប៉ារាអីចឹងហៅគ្នាឡើងទៅហាត់ទៅរៀនណានោះស្រូវអង្ករគ្នាធ្វើបានក៏ប្រូតកាត់មិនសូវបានល្អខូចខាតស្រូវភ្លើងឆេះអីចោលខ្លះទៅ ។

ប៊ុនថនៈ បាទ ។

សារ៉េតៈ ហើយរឿងទ័ពតែមកហើយបើមិនសុំបាយក៏សុំអង្ករមិនដែលខាន ម្លោះហើយគ្នារស់នៅជីវភាពឃើញថាដុនដាបដល់ផុតពីសង្គ្រាមអស់ហើយមានពីណាសុំអីមួយៗធ្វើអីបានហ្នឹងៗឃើញថាមានការរីកចំរើនទៅមុខរហូត ។

ប៊ុនថនៈ បាទ!ចឹងខ្ញុំអស់អីសួរលោកពូហើយ ។

សារ៉េតៈ បាទ ។

ប៊ុនថនៈ ហើយខ្ញុំអរគុណលោកពូច្រើន ។

សារ៉េតៈ បាទ ។

**ចប់**